# មជ្ឈមណ្ឌលឯកសារកម្ពុជា

# អាំ ហាន

*សម្ភាសជាមួយ **អាំ ហាន** ភេទស្រី អាយុ ៦០ឆ្នាំ*

*នៅភូមិត្រពាំងគូ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ*

*នៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៥*

*សម្ភាសដោយៈ ស៊ិរ សាវីណា និង សាន់ កល្យាណ*

សាវីណាៈ អញ្ជើញជំបូនខ្ញុំចង់ស្គាល់ឈ្មោះអ៊ុំសិន?

ហានៈ ខ្ញុំឈ្មោះ អាំ ហាន

សាវីណាៈ អ៊ុំអាយុប៉ុន្មានហើយ?

ហានៈ ៥០ ឆ្នាំហើយ

សាវីណាៈ អ៊ុំរៀបការអាយុប៉ុន្មានហើយ?

ហានៈ រៀបការកាលពីអាយុ១៦ មិនដឹងឆ្នាំប៉ុន្មានទេ ខ្ញុំភ្លេចហើយ

សាវីណាៈ ក្រួសាអ៊ុំឈ្មោះអីដែរអ៊ុំ?

ហានៈ ក្រួសារខ្ញុំឈ្មោះ ញ៉ែម ពុធ

សាវីណាៈ គាត់អាយុប៉ុន្មាន?

ហានៈ គាត់អាយុបងខ្ញុំ១១ឆ្នាំ

សាវីណាៈ ឥឡូវគាត់នៅណា?

ហានៈ គាត់គេយកទៅសម្លាប់តាំងពី ឆ្នាំ ៧៦ណោះ

សាវីណាៈ ស្រុកកំណើតគាត់នៅឯណាមីង?

ហានៈ ស្រុកកំណើតគាត់នៅធ្នង់រលើង ឃុំលាយបូរនេះ

សាវីណាៈ ចុះស្រុកកំណើតអ៊ុំ?

ហានៈ ស្រុកកំណើតខ្ញុំនៅត្រាំកក់

សាវីណាៈ ភូមិអីអ៊ុំ?

ហានៈ កាលពីមុនអូន នៅផ្សារត្រាំកក់និងតែម្ដង

សាវីណាៈ ក្នុងឃុំអីដែរអ៊ុំ?

ហានៈ ឃុំត្រាំកក់និង

សាវីណាៈ អត់មានឈ្មោះភូមិទេហេះ?

ហាន៖ ភូមិកាលពីមុនគេដាក់ភូមិត្រាំកក់ម៉ង តែកំណើតដើមដែលឪពុកខ្ញុំនៅនិងណា៎ គេហៅភូមិនាល ចា៎ បងប្អូនខ្ញុំឥឡូវគេនៅភូមិនាលនិង

សាវីណា៖ ឃុំអី?

ហាន៖ ឃុំត្រាំកក់និង ស្រុកត្រាំកក់និង ខេត្តតាកែវ

សាវីណា៖ អ៊ុំឥឡូវធ្វើអីដែរអ៊ុំ?

ហាន៖ ខ្ញុំអត់មានធ្វើអីទេ ឥឡូវគេឲ្យធ្វើសមាគមភូមិ គេចេះតែឲ្យធ្វើទៅ

សាវីណា៖ អ៊ុំអត់មានធ្វើស្រែទេហេះ?

ហាន៖ ខ្ញុំធ្វើស្រែ នៅជាមួយកូន តែអត់មានធ្វើអីដែរទេ មានតែធ្វើកន្ត្រកអីបន្តិចបន្តួច

សាវីណា៖ អ៊ុំធ្វើកន្ត្រកហេះ?

ហាន៖ ចា៎ ធ្វើកន្ត្រកលក់នាយអាយនិង

សាវីណា៖ អ៊ុំថាម៉ិញប្ដីរបស់អ៊ុំគេយកទៅពីថ្ងៃណា?

ហាន៖ ឆ្នាំ ១៩៧៦

សាវីណា៖ គេយកពីណាទៅអ៊ុំ?

ហាន៖ គេយកពីភូមិណោះ ភូមិខ្ញុំនៅកន្លែងនោះ បែកមកខ្ញុំនៅបានមួយឆ្នាំ រៀបបាយហូបបាយរួមនិង គេយកទៅពេលព្រឹកម៉ោង៩ ហើយគេនាំទៅ គេថាប្ដីខ្ញុំនិងទៅសែនជីនៅពាណិជកម្មគេនៅសាលាឃុំលាយបូរឥឡូវនិង ដល់ហើយគេយកទៅរហូតទៅ

សាវីណា៖ គេយកទៅនិងអ៊ុំឃើញទេ?

ហាន៖ គេយកទៅនិងខ្ញុំឃើញតែគេបណ្ដើរទៅ ទៅនិងគាត់នៅវែកកណ្ដាប់ណា ហើយខ្ញុំនៅជញ្ជូនកណ្ដាប់កន្លែងសហករណ៍និង ហើយដល់ពេលគេយកទៅអញ្ចឹង អាប្អូនខ្ញុំនិងវាប្រាប់ថា លោកបងគេយកទៅហើយ ហើយខ្ញុំមកនិងខ្ញុំអត់មានដឹងថាគេយកទៅ តែគេឃើញឈ្លបគេនិង គេដើរអើតៗអញ្ចឹង រកគ្រួសារខ្ញុំនិងណា ដល់ហើយទើបគេប្រាប់ថា គ្រួសារខ្ញុំនៅកណ្ដាលវាលស្រែណោះ ហើយគេយកទៅៗ យកទៅដកវែក ដងអង្រែកនិងផង យកទៅគេឲ្យទៅសែនជី តែមិនមែនទេ គេយកទៅ គេទៅជាមួយគណៈអាពតនិងណា ហើយគេយកទៅបាត់រហូតទៅ តែយប់ឡើងអាប្អូនខ្ញុំនិងខ្លាចគេថាកុំឲ្យខ្ញុំនិងយំ គេខ្លាចគេយកខ្ញុំទៀតណា ហើយខ្ញុំអត់ហ៊ានយំទេ យកតាំងពីកូនខ្ញុំមីងមួយនៅជាមួយនិង តាំងពីវានៅតូច នៅកុមារណោះ នៅអាយុ៥ឆ្នាំ

សាវីណា៖ គេយកគាត់និងគេហៅឃុំអី?

ហាន៖ ឃុំត្រពាំងគូរ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្ត

សាវីណាៈ អញ្ចឹងមានន័យថា កាលពីជំនាន់និង អ៊ុំនៅនិងដែរហេះ អត់មានទៅណាទេហេះ?

ហានៈ ចា៎ អត់មានទៅណាទៅ ខ្ញុំនៅនិងរហូតទៅ

សាវីណាៈ ចុះអ៊ុំមានកូនចៅប៉ុន្មាននាក់ដែរអ៊ុំ?

ហានៈ ខ្ញុំកូន៥នាក់

សាវីណាៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ហានៈ ស្រី៤ ប្រុស តែមួយទេ

សាវីណាៈ កូននិងកើតទាន់ជំនាន់ប៉ុលពតប៉ុន្មាននាក់?

ហានៈ កូននិងកើតទាន់ជំនាន់ប៉ុលពតទាំងអស់ មីពៅនិងអាយុ៥ឆ្នាំទេ

សាវីណាៈ ចុះកូនអ៊ុំនៅទាំងអស់តើអី?

ហានៈ កូនខ្ញុំនៅទាំងអស់

សាវីណាៈ ចុះបងប្អូនអ៊ុំប៉ុន្មាននាក់?

ហានៈ បងប្អូនខ្ញុំ៧នាក់

សាវីណាៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ហានៈ ស្រី ៣ ប្រុស៤

សាវីណាៈ ចុះឥឡូវនៅប៉ុន្មាន?

ហានៈ ឥឡូវនៅ៤

សាវីណាៈ ៤និងស្រីប៉ុន្មាន?

ហានៈ ប្រុស១ ស្រី៣

សាវីណាៈ ស្រី៣នាក់និងឈ្មោះអីខ្លះអ៊ុំ?

ហានៈ ឈ្មោះ អាំហ៊ាន អាំហាម ហើយខ្ញុំនិង ប្រុសឈ្មោះ អាំស៊ីម

សាវីណាៈ ២នាក់និងនៅឯណា?

ហានៈ នៅភូមិកើលកទាំងពីរអូន

សាវីណាៈ ឃុំអីគេ?

ហានៈ ឃុំត្រាំកក់

សាវីណាៈ ចុះអ៊ុំថានៅភូមិនាល?

ហានៈ ភូមិនាលនិងបងខ្ញុំនៅនិង តែវាជាប់គ្នានិងអានិងអូន ភូមិនាលនិងបងខ្ញុំស្លាប់ហើយ នៅមេម៉ាយបងថ្លៃ

សាវីណាៈ បងថ្លៃឈ្មោះអី?

ហាន៖ បងថ្លៃនិងឈ្មោះ ប៉ូ សារី ។ គាត់ជាជនួងខ្ញុំទៀតណាំ ហើយគាត់មេម៉ាយនិង ឪពុក គាត់ក៏ឪពុកយកដែរ

សារីណា៖ បងប្អូនអ៊ុំ៣នាក់ដែលថាស្លាប់និង ស្លាប់ដោយសារអីដែរ?

ហាន៖ ស្លាប់ដោយអាពតយកទាំងអស់អូន ។ ហើយមួយនោះដាច់ជើង គាត់ទៅក-៥និង ដាច់ជើងទាំងពីរនិង

សារីណា៖ ចុះម្នាក់ទៀត?

ហាន៖ ម្នាក់ទៀតអាពតយក..........បើគ្រួសារប្អូននិង អានិងក៏យកទៅវ៉ៃចោលទាំងអស់ដែរ យកទៅស្រុករគ្នានិង ឪពុកខ្ញុំនិងតែម្តង ឪពុកខ្ញុំគេថា គេចងទៅ យកទៅដាក់នៅ ក្រាំងតាចាន់ តែមិនដឹងថាគេយកគាត់ទៅសម្លាប់ឯណាផង មិនដឹងគេយកទៅណាបាត់ រហូតទៅ

សារីណា៖ ហើយបងប្អូនអ៊ុំគេយកទៅនិង?

ហាន៖ គេយកទៅនិងសម្លាប់និង........... ។

សារីណា៖ បងប្អូនអ៊ុំ៧នាក់?

ហាន៖ ចាំ ស្លាប់៣នាក់ ប្អូន១ មីងប្អូនមួយពៅនោះនិងស្លាប់ទាំងប្ដី ទាំងកូនក្មួយផង និងបាត់ តែម្តង មួយគ្រួសារនិង អត់មានពូជនៅទេណាអូន ដាច់ពូជតែម្តង

សារីណា៖ ប្អូនពៅនិងហេះ?

ហាន៖ ចាំ ប្អូនពៅ យកទាំង៣តែម្តង

សារីណា៖ យកពីណាទៅអ៊ុំ?

ហាន៖ យកពីភូមិនៅត្រាំកក់ណោះ

សារីណា៖ ភូមិអី?

ហាន៖ ភូមិកាល់គមនិងម៉ង ឃុំត្រាំកក់និង

សារីណា៖ គាត់នៅនិងអញ្ចឹង?

ហាន៖ កាលពីមុនគាត់នៅនិង

សារីណា៖ ចុះធ្វើម៉ិចអ៊ុំដឹង?

ហាន៖ ខ្ញុំដឹងព្រោះអីខ្ញុំនៅនេះ គេយកទៅ បានគេប្រាប់ខ្ញុំកុំឲ្យទៅស្រុកវិញណា

សារីណា៖ នរណាគេអ្នកប្រាប់?

ហាន៖ ម្តាយខ្ញុំនិង កាលពីម្តាយខ្ញុំនៅនិងណាថា កូនឯងកុំទៅនោះ ទៅនោះគេយកអស់ ហើយ ហើយកូនឯងគេចខ្លួនទៅ កុំទៅណោះអី ហើយដល់ហើយខ្ញុំមកនៅខាងប្ដីនិង

ហើយអាតំណាងកងនិងគេនិង តាមមកឃើញខ្ញុំគេយកប្តីខ្ញុំទៀតទៅ គេយកពេលម៉ោង៩ព្រឹកនិង

សាវីណាៈ តំណាងកងពីណា?

ហានៈ តំណាងកងភូមិគេ ដំណាងនិងគេមកពីត្រាំកក់ដែរ

សាវីណាៈ គេតាមមករកអ៊ីទៀត?

ហានៈ អានិងប្រធានឃុំណាអូន អានិងប្រធានឃុំគេតាមមករកដល់ភូមិយើងនេះ

សាវីណាៈ ឥឡូវនៅរស់ទេ?

ហានៈ អានិងនៅរស់ឥឡូវ តែគេយកទៅជាប់គុកនៅទន្ទាប់ណោះ កាលពីវៀតណាមកយកទៅនិង ហើយជាប់គុកនៅទន្ទាប់និង ទើបតែរស់តើអានិង វានៅតែផ្ទះទេ

សាវីណាៈ នៅឯណា?

ហានៈ នៅត្រាំកក់ នៅក្បែរដំបូក៨ នៅក្បែរវត្តអង្គរនាប

សាវីណាៈ នៅភូមិអី?

ហានៈ ភូមិត្រពាំងខ្លាយ

សាវីណាៈ គេតាមមករកអ៊ីហេះ?

ហានៈ អត់តាមទេ គេមកធ្វើឃុំ គេផ្លាស់ឲ្យមកកាន់ឃុំនៅនិងណា

សាវីណាៈ អូ! ឃុំលាយបូរនិងហេះ?

ហានៈ ចា៎ ឃុំលាយបូរនិងម៉ង

សាវីណាៈ ជំនាន់អាពតនិងហេះ?

ហានៈ ចា៎ ហើយដល់មកវាឃើញខ្ញុំ សួរថាម៉ិចក៏មិនទៅស្រុកវិញ ខ្ញុំថាបងប្អូននៅនេះ ហើយកាលនិងខ្ញុំខ្លាចណាស់ អត់ហ៊ានទៅទេ បើម្តាយខ្ញុំនិងលួចប្រាប់ថា កូនឯងកុំទៅ ខ្ញុំអត់ទៅទេ ខ្លាចគេតាមមកយកទៀត

សាវីណាៈ ប្អូនស្រីអ៊ីដែលថាស្លាប់ដាច់ពូជនិងឈ្មោះអីដែរ?

ហានៈ ឈ្មោះ អាំ ហ៊ុន អានិងវាផុតម៉ងណាអូនៗ អាំ ហ៊ុននិងយកទាំងប្តីវា កូននៅតូច អញ្ចឹងគេថាដាំបាយដាក់អាចម៍ជ្រូកឲ្យវាស៊ីទៅ តែចាដាំនិងវេចសាច់មាន់ ហើយគេ ថាកូនខ្ញុំនិងវេចបាយអញ្ចឹងគេឲ្យដាក់ឈ្មោះ ដូចអូនឯងឈ្មោះអីអញ្ចឹង ដូចអូនឯងឈ្មោះអីអញ្ចឹង ដាក់ឈ្មោះទៅ កូនខ្ញុំឈ្មោះអីអញ្ចឹងដាក់ឈ្មោះទៅណា ដល់ទៅដល់នោះអញ្ចឹង មិនដឹង បែបមានអ្នកស្អប់ហើយអូន វាដូរសាច់មាន់ចេញទៅ វាដាក់

អាចម៍និងចូលក៏មិនដឹងដែរអូនណា ហើយគេចោទថាយើងដាក់អាចម៍ជ្រូកនិងតែម្តង ដាំបាយដាក់អាចម៍ជ្រូកឲ្យគេស៊ី

សាវីណា: ឲ្យនរណាគេស៊ី?

ហាន: ឲ្យពតនិង ឲ្យមេកងទព្វគេ ដូចថាកងទព្វគេទៅណាគេឲ្យយើងវេចបាយឲ្យគេណាអូន មួយផ្ទះអញ្ចឹងគេឲ្យវេចមួយសំណុំអញ្ចឹងទៅ ហើយគេយកទៅៗ ។ ដល់នេះស្លាប់ ខ្ញុំដឹងព្រោះ ម្តាយខ្ញុំគាត់អ្នកប្រាប់ណា ម្តាយខ្ញុំរត់មកនៅនេះដែរនិងណា៎ និងគាត់មកស្លាប់នៅនេះទៅ ហើយកូនប្រុសខ្ញុំនិងវាបែកទៅនៅនោះមួយ

សាវីណា: កូនទីប៉ុន្មាន?

ហាន: កូនទី១

សាវីណា: ឈ្មោះអី?

ហាន: ឈ្មោះ សុខាន ហើយទៅនៅជាមួយម្តាយខ្ញុំនិងណា ហើយដល់ពេលខ្ញុំយកម្តាយខ្ញុំមកបានគេមកតាមទៅ វាថាវានៅជាមួយយាយវា កាលខ្ញុំគេយកទៅហើយ កាលពីប៉ុលពតនិង ខ្ញុំមកនៅនេះនិង កាលនិងខ្ញុំនៅនិងភ្នំពេញបាន២-៣ខែ គេយកឪពុកខ្ញុំ

សាវីណា: អញ្ចឹងមានន័យថា ពេលពេលដែលអ៊ុំការហើយ អ៊ុំទៅនៅភ្នំពេញអញ្ចឹង?

ហាន: អត់ទេ ការហើយនៅស្រុក នៅនិងផ្សារនិង

សាវីណា: នៅផ្សាត្រាំកក់?

ហាន: ចា៎ គាត់បង្រៀននៅវត្តត្រាំកក់និង វត្តឯកខត្តម

សាវីណា: ហើយបន្ទាប់មក?

ហាន: បន្ទាប់ដល់ពេលដែលគេវៃវៀតណាមចូលមកពីមុននិង ហើយដល់ពេលវៃយៀកណាមធ្មេញខ្មៅចូលមកនិងណាអូន ខ្ញុំរត់ទៅនៅភ្នំពេញ

សាវីណា: ជំនាន់ណាអ៊ុំ?

ហាន: មុននិងអាពតយើងចូលនិង

សាវីណា: ចូលលន់ណុលនៅ?

ហាន: លន់ណុលខ្ញុំមកនៅកែបនេះ

សាវីណា: អញ្ចឹងមិនទាន់ដល់លន់ណុលទេហេះ?

ហាន: ចា៎ អត់ទេ ប្តីខ្ញុំគេយកកាលអាពតនេះទេ និយាយកាលពីខ្ញុំរត់ទៅនៅភ្នំពេញនិងកាលនិងគ្រួសារខ្ញុំ......ដល់ហើយខ្ញុំរត់ទៅនៅភ្នំពេញ ទៅនៅភ្នំពេញនិងបានតែ២ខែ ដល់គេវៃអង្គតាសោម ខ្ញុំមកនៅអង្គតាសោមនេះណា៎ ដល់គេវៃបែកអង្គតាសោម

ទើបខ្ញុំមកនៅតាកែវ លន់ណុលនិងនៅតាកែវហើយ ។ នៅតាកែវនិងទាល់តែតែបែក តែម្តង បែកជន្លៀសខ្ញុំទៅ ខ្ញុំទៅឆ្ងាយដល់ឃុំលំចង់ណោះ ប្អូនថ្លៃខ្ញុំនៅនិងណា ខ្ញុំទៅតាមគេនៅនិង នៅឃុំលំចង់និងគេថាឲ្យមកធ្វើផ្ទះនៅតាមភូមិវិញទៅ ដល់ហើយខ្ញុំក៏គ្រួសារខ្ញុំនិងវាអត់ហ៊ានទៅនោះវិញ ហើយគាត់ថាឲ្យមកនៅនេះមក មកនៅភូមិនិង ណាំ ហើយចុះមកដេស្ទីកអីមកនៅភូមិនេះទៅ មកនៅបានតែមួយឆ្នាំតើអូន គេយក គាត់ទៅ

សាវីណា: អញ្ចឹងអត់ទៅស្រុកកំណើតប្តីទេហេះ?

ហានៈ ស្រុកកំណើតប្តីនៅធ្នង់រលើងនិង ជិតនេះដែរនិង តែអត់ទៅនេះទេ នៅនេះទៅជាមួយបងប្អូនខាងប្អូនថ្លៃនិងណា ពូមុិញនិងគាត់ត្រូវជាជន្ទងខ្ញុំ តែវាត្រូវរបស់ប្អូនថ្លៃខ្ញុំណា ហើយខ្ញុំនៅនិងរហូតទៅ ដល់នៅទៅទើបគេមកឃើញគេយកប្តីខ្ញុំ នៅបាន១ឆ្នាំ

សាវីណា: ពេលអ៊ុំរត់ទៅភ្នំពេញ ទៅអង្គតាសោម ទៅតាកែវអី សុទ្ធតែទៅជាមួយប្តីទាំងអស់ហេះ?

ហានៈ ទៅជាមួយប្តីទាំងអស់

សាវីណា: ជាមួយកូនអី?

ហានៈ ចាំ ព្រាត់គ្នាម្តងដែរ កាលពីគាត់មកអង្គតាសោមដំបូងណា គាត់មកលន់ណុលនិងគេឲ្យគាត់មកយាមជាមួយទាហានណោះ គេឲ្យទៅធ្វើកុម៉ង់ដូនៅនិង គាត់មកប្រាប់គ្នាម្តងដែរ ខ្ញុំនៅភ្នំពេញ គាត់មកនេះ មកបានតែមួយខែទេ គាត់មកតាមនិង ហើយដល់ពេលនៅនេះ ចូលមកធ្វើស្រែឆ្ងាយដល់ភូមិបឹងយើងនេះ ចុះមកធ្វើស្រែ ។ ភូមិបឹងនិងជន្លៀសមកធ្វើ មកលួច មកធ្វើបន្តិចៗទៅណា មានអាពតដេញបាញ់អីផង ថ្ងៃល្ងាចថ្មើនិងអីអត់ហ៊ាននៅទេ រត់ទៅវិញហើយ កាលនិងគេដាក់លីងត្រឹមថ្នល់រទេះភ្លើងអញ្ចេះអូនណា ដីមកខាងនេះសុទ្ធតែដីអាពតទាំងអស់ ហើយត្រឹមរទេះភ្លើងទៅណោះទើបដីលន់ណុល

សាវីណា: ជំនាន់ណាដែរអ៊ុំ?

ហានៈ ជំនាន់លន់ណុលនិង

សាវីណា: ប្រហែលជាឆ្នាំប៉ុន្មាន អ៊ុំចាំទេ?

ហានៈ ដូចជា៧១ អីនិង?

សាវីណា: កាលនិងបែកអង្គតាសោមហើយឬនៅ?

ហានៈ បែកហើយ

សាវីណា: បែកអង្គតាសោមនិងក្រោយទម្លាក់សម្តេចប៉ុន្មានឆ្នាំ?

ហានៈ ក្រោយនិងមិនដឹងជាប៉ុន្មានឆ្នាំដែរ ខ្ញុំភ្លេចហើយខ្ញុំ យូរពេកហើយ នេះកាលនិងឆ្នាំកំណើតកូនខ្ញុំនេះ ឆ្នាំជូតនិង អានិងកើតលន់ណុលហើយ ខ្ញុំនៅអង្គរតាសោម រត់វាទំងន់ទៅកើតនៅតាកែវណោះ អត់ហ៊ាននៅនេះ ខ្លាចគេបាញ់អត់មានឈប់ រត់ទៅនៅតាកែវៗ ......អាប្អូនដីជូនមួយមួយ ហើយឡានទៅដឹកក្រាប់និង ទំដិះឡានជាមួយគេ រត់ទៅ ភ្លៀងរលឹមសស្រេចទាំងកូនផង ហើយគេបាញ់បាក់ដៃតែកុងឡាន ហក់ចុះឡើងក្រាបទើបឡើងទៅទៀត ទៅដល់តាកែវណោះអូន ហើយភ្លៀងអើយភ្លៀង ហើយនិងគេវៃអង្គតាសោម១២យប់ណាអូន ហើយដល់វៃហើយនិង ប្តីខ្ញុំជាប់នៅនេះ

សាវីណាៈ ជាប់នៅណា?

ហានៈ ជាប់នៅអង្គតាសោមនិង នៅវៃជាមួយគេ ទៅតាកែវទៅតែខ្ញុំទេ

សាវីណាៈ អញ្ចឹងប្តីអ៊ុំធ្វើអាហាន?

ហានៈ ធ្វើគ្រូ តែគេឲ្យកុម្មង់ដូកាលនិងអូនណា គេអត់ឲ្យបង្រៀនទេ គេឲ្យកាន់យាមដែរនិង ណាដល់ហើយគេបាញ់១២យប់នៅនិង បាញ់កាលពីលន់ណុលនិង អាពតបាញ់១២យប់ទើបបែក ហើយគាត់អត់អី ទើបគាត់រត់ទៅតាកែវទៅ នាំគ្នារស់នៅតាកែវរហូតទៅណាកូន ហែរហូបទៅ ដល់អាពតជន្លៀសចូលមកអាពតនិងតែម្តងទៅ

សាវីណាៈ ប្តីអ៊ុំឈ្មោះអី?

ហានៈ ឈ្មោះ ញ៉ែម ពុធ

សាវីណាៈ អញ្ចឹងបានន័យថាជំនាន់គេគេវៃអង្គរតាសោមនិងលែងបានបង្រៀនអីហើយ?

ហានៈ លែងបានបង្រៀនអីហើយអូន អង្គតាសោមនិងអត់មានសាលាបង្រៀនទេ គ្រូគេឲ្យធ្វើកុម្មង់ដូរទាំងអស់

សាវីណាៈ ចុះកាលពីមុនគាត់បង្រៀននៅឯណា?

ហានៈ កាលពីមុនគាត់បង្រៀននៅត្រាំកក់ណោះ វត្តឯកឧត្តម ហើយដល់ពេលចូលក្នុងនេះអត់បង្រៀនទេអូន គេឲ្យយាមអញ្ចឹងតែម្តង មានអ្នកបង្រៀនគឺបង្រៀន មានអ្នកអត់បង្រៀនព្រោះគ្រូវាច្រើនណា ដល់ពេលមូលគ្នាទៅនៅតាកែវនិង គេឲ្យគាត់ទៅធ្វើកុម្មង់ដូរ យប់ឡើងយាមៗ មានលីងមួយសំរាប់គ្រូអញ្ចឹងចូលប៉ុកនិងតែម្តង ទៅយប់ណា ហើយគ្រាប់ផ្លោងអាពតទំលាក់ម្តង គ្រួសារខ្ញុំអត់អីណា ម៉ោងគាត់យាមតែធ្លាក់ខុសកន្លែងប៉ះដីនិងណា ត្រង់សេនិងគាត់អត់អី ហើយគ្រូៗអស់នោះដែលគាត់ដាក់ប៉ោអ៊ីចង់អង្រឹងនិងរោងនិង ស្លាប់អស់២នាក់ហើយរបួសជាង១០នាក់ ណោះ

អាគ្រាប់ផ្ទោងនិងធ្លាប់ក្បែរពេងនិងតែម្ដង ហើយត្រូវគាត់ គាត់អត់អីកាលនិងត្រូវម៉ោងគាត់យាម គាត់នៅក្នុងលីងនិង

សាវីណាៈ ចុះពេលដែលអ៊ុរត់ទៅដល់តាកែវប៉ុន្មានឆ្នាំទើបបែក?

ហានៈ រត់ទៅតាកែវដូចតែ.....ខ្ញុំនៅប្រហែលជា២-៣ឆ្នាំ ខ្ញុំភ្លេចហើយ ដូចនៅបានតែ២ឆ្នាំទេអូនបែកតាកែវ

សាវីណាៈ បែកហើយចុះមកនេះវិញ?

ហានៈ បែកចុះទៅនៅវ៉ចង់និងណា ហើយទើបមកនៅនេះ មកនៅនេះអត់បានយូរទេ បានប្រហែលជាកន្លះខែទេអូន ហើយគេឲ្យមកនេះវិញមកណា៎ គេឲ្យនៅតាមស្រុកភូមិវិញទៅណា ហើយខ្ញុំមកនេះជាមួយគេមក

សាវីណាៈ ចុះហេតុអីពេលដែលបែកតាកែវភ្លាម អ៊ុំមិនមកនេះមក?

ហានៈ អត់ទាន់មកនេះទេ ព្រោះអីនៅកន្លែងនេះអត់មានមនុស្សនៅផង កន្លែងនេះទឹកដីសមរភូមិគេណាអូន គេហៅថាទឹកដីខ្មាំងកាលពីអាពត អានិងផ្ទះគ្មានទេអូន ផ្ទះដុតឆេះទាំងអស់ ឆេះគ្មានសល់ផ្ទះណាមួយទេ ហើយសុទ្ធតែព្រៃទាំងអស់ ហើយស្រែនេះអត់មាននរណាធ្វើទេកាលនិង ដុះស្មៅមើលស្រែគ្មានទេ ត្រពាំងទឹកវីងត្រីងាប់ស្អុយនៅនិងទាំងអស់ អត់មាននរណាហ៊ានចូលទេដីសមរភូមិគេអូនណា ហើយដល់ហើយទៅនៅណោះនៅណោះហើយទើបចូលមក ៗ និយាយពីខ្មោតណាអូន ដុះនៅក្រោមដើម អាគ្រាប់ខ្មោតនិងដុះដំរុំដូចយើងនេះអញ្ចឹង វាដុះឡើងគ្រាប់និង អត់មាននរណាមកកាប់នរណាមករំលើងអីទេ អត់មាននរណាហ៊ានចូលទេ ហើយមកមុនដំបូងអាណោចអាធម៌ណាអូនអើយ គ្មានផ្ទះមួយទេ ហើយគ្មានដើមឈើ គ្មានអីអញ្ចឹងទេ វាលទាំងអស់ព្រៃចេកអីស្វិតអស់រលីងហើយ គេដុតណា៎ ហើយផ្លូវគេស្មៅអញ្ចឹង មានប្រហោងអញ្ចឹងដើរទៅ ក្រៅពីនិងសុទ្ធតែស្មៅទាំងអស់ មានតែផ្លូវជំនាន់អាពតគេដើរចុះដើរ ឡើងប៉ុស្តិគេណាអូន សុទ្ធតែព្រៃតែម្ដង ត្របែកអីទំជ្រុះពេញដី ក្រាលដីទាំងអស់គ្មាននរណាដែលហ៊ានចូល អត់ហ៊ានចូលទេ ប្រឡោះនិង ហើយខ្ញុំមកនៅនិងតំបូង ហើយខ្ញុំនៅនិងរហូតទៅលែងទៅណាទៅតាំងពីពេលនិងមក ជំនាន់អាពតនិងនៅនិងតែខ្ញុំអត់បាននៅនិងភូមិទេ ដល់គេរើសកងពិសេស ចុះហើយគេទំលាយ កាលពីគេរើស១៨ និង ១៧នោះ ខ្ញុំគេឲ្យទៅនៅភូមិត្រពាំងគ្រាចខាងជើងនេះ

កល្យានៈ អ៊ុំមិនមែនអ្នកមូលដ្ឋានទេអញ្ចឹង?

ហាន: ខ្ញុំមិនមែនអ្នកមូលដ្ឋានទេ ខ្ញុំថ្មីណា ខ្ញុំដោយសារអញ្ចឹងតើបានជាគេតាមមកយកគ្រួសារទៀតនិងណា៎ ហើយខ្ញុំនៅកន្លែងត្រពាំងគ្រាចនិង នៅនិងបាន១ឆ្នាំ គេឲ្យទៅកង ហើយកូនទុកនៅនិងកងគេណា មកដល់វិញកូនខ្ញុំបាត់អស់រលីងពីផ្ទះ មកដល់យប់ថ្ងៃ ១០ ថ្ងៃ២០ ថ្ងៃ៣០ទើបគេឲ្យមកផ្ទះ នៅឯស្រែប្រាំងខាងកើតតាកែវណោះ ហើយមកអញ្ចឹងយប់អញ្ចឹងមកជួបកូនទៅ ព្រលឹមឡើងងងឹតៗគេឲ្យឡើងទៅវិញ ទៅនៅណោះវិញ ហើយកូនទុកនៅនិងទៅ ហើយមីមួយកំពុងសម្ភាសនិង (ញ៉ែម ចាន់តារា) មីងនិងគេឲ្យទៅនៅវត្តខ្នារណោះ ស្រកើចខាំគ្នាណោះ ស្គមណាស់ថាដូចទឹក បាយ វាក្រិនណាអូន ដល់ហើយវាអាយុ២០ទើបបានមានរដូវណា ហើយស្គម វាស្គមពេកហើយវាអត់ៗ ចុះបើសង្កើចអូនអើយ និយាយពីចង្កេះ សំពតវាអញ្ចឹងលើកឡើងក្រហមប្រាកម៉ង់អូនអើយយប់ឡើង សង្កើចខាំនោះស្គមអើយស្គម ខ្ញុំអាណិតកូនឡើងខ្លាចចិត្តហើយ ដល់ហើយបានទៅនៅត្រពាំងគ្រាចនិង គេឲ្យទៅរំចង់ ខ្ញុំមិនទៅទេ

សាវីណា: មុិចបានជាគេឲ្យទៅ?

ហាន: គេថាឲ្យខ្ញុំនិងទៅនៅរំចង់និង លត់ដំ ទៅនៅលំចង់និងអត់មានបាយហូបណាអូន និងបបរសុទ្ធតែទឹកហើយ ខ្ញុំអត់ទៅ នៅនិងក៏បបរដែរតែគេបបរគេខាប់ជាងទៅរំចង់បន្តិច

សាវីណា: មុិចបានជាអ៊ុំដឹងថាទៅរំចង់បបរសុទ្ធតែទឹក?

ហាន: បានដឹងនិង មានអ្នកមកពីនិងគេប្រាប់ណា ដល់ហើយខ្ញុំអត់ទៅ ខ្ញុំថាខ្ញុំសុខចិត្តនៅជាមួយបងប្អូនណោះ បើសិនជាឲ្យខ្ញុំទៅខ្ញុំអត់ទៅទេ បើគេសម្លាប់នឹកឃើញថាក៏សម្លាប់ ទៅខ្ញុំលែងគិតហើយ ខ្ញុំថាងាប់ចោលកូនក៏ស្លាប់ចុះ ខ្ញុំអត់គិតទេ ខ្ញុំលែងទៅហើយ ដល់ហើយខ្ញុំអតទៅ

សាវីណា: ហេតុអីបានជាគេចង់ឲ្យអ៊ុំទៅនៅរំចង់?

ហាន: មានខុសអី អានិងវាពាក់ព័ន្ធម៉ង់អូន គេរើសទៅម៉ង់អូន

សាវីណា: និងក្រោយពីគេសម្លាប់ប្ដីអ៊ុំហើយហេះ?

ហាន: ចា៎ សម្លាប់អស់ហើយនិងណា៎ គេសម្លាប់តាំងពីនៅភូមិនេះណោះ

សាវីណា: អញ្ចឹងកាលពីគេសម្លាប់ប្ដីអ៊ុំអ៊ុំមិនទាន់មកនៅត្រពាំងគ្រាចទេ?

ហាន: អត់ទាន់ទៅនៅទេ ដល់ហើយបានគេបំបែកនិង ដល់ហើយទើបគេឲ្យទៅនៅ ១៧និង ១៨និងណាអូន អានិងគេបង្កើតសិទ្ធហើយ ហើយដល់ពេលខ្ញុំអត់ទៅនិង គេបំបែកសិទ្ធណាអូន គេបំបែកសិទ្ធវិញ

កល្យាន: បំបែកសិទ្ធបានន័យថាម៉ិចអ៊ី?

ហាន: បំបែកអា១៨ និង ១៧ អាថ្មីអាចាស់និងឲ្យចូលគ្នាវិញ ឲ្យនៅជាមួយគ្នាវិញណាអូន

សាវីណា: គេឲ្យមានសិទ្ធដូចគ្នាហេះ?

ហាន: ចាំ ឲ្យចូលនៅមូលគ្នាវិញ នៅហើយខ្ញុំក៏ទៅនៅវត្តខ្នាណោះ ប្អូនខ្ញុំទៅនៅនិងណាអូន ប្អូនថ្លៃនិង ខ្ញុំទៅនិងជាមួយគេទៅ អានិងរំលាយសិទ្ធហើយ ខ្ញុំអត់ទៅនៅរំចង់ទេ ខ្ញុំទៅនៅនិងទៅៗ ទៅនៅនិងបានជួបអាប្រធានគេយកប្តីខ្ញុំនិងទៀត គេតាមដានខ្ញុំមាំណាស់ ខ្ញុំដើរច្រូតដើរអីនិង គេឲ្យអ្នកបោកស្រូវនិង គេដាក់កងអញ្ចឹង ចុះខ្ញុំជាមួយក្រុមយាយៗណាអូន ជាមួយយាយៗ១០នាក់អញ្ចឹង គេឲ្យរែក១ថ្ងៃម្នាក់ អានិងច្រូត ណាំ ហើយខ្ញុំអាណិតយាយៗពេក ខ្ញុំរែកជំនួសគាត់ណា ដូចថាឈ្មោះគាត់ថ្ងៃនិងត្រូវ គាត់រែក ខ្ញុំអ្នករែកទៅ ហើយដល់ឈ្មោះខ្ញុំខ្ញុំរែកទៀតទៅ យាយៗនៅនិង៣នាក់ ណោះ ខ្ញុំជួយរែកគាត់អាណិតគាត់ពេក ចាស់ៗគេឲ្យរែកនឹកឃើញអាណិតគាត់ ទៅ ជួយរែកគេ តែអត់ហ៊ានប្រាប់គេទេណាអូន ខ្លាច លាក់ការណ៍កាលនិង សុទ្ធតែលាក់ ការណ៍ហើយ ហើយខ្ញុំទៅនៅនិង កូនខ្ញុំនៅខ្នារនិង នៅនិងកងដដែល

សាវីណា: ឃុំអីអ៊ី?

ហាន: វត្តខ្នារនិងឃុំលាយបូរដែរ កូនទី២

សាវីណា: យកទៅតែមួយទេហេះ?

ហាន: អត់ទេ នៅនិងគេយកតែមួយទេ មីតូចៗនេះនៅតាមកងណាអូន ហើយមីធំតូចៗនេះ នៅផ្ទះទាំងអស់ តែនៅកងដែរ

សាវីណា: ចុះកូនបង?

ហាន: អាបងបំផុតវាកាលនិងទៅនៅជាមួយម្តាយខ្ញុំ វាអត់ទាន់មកនេះដងនិង មកដល់ពេល បែកហើយនិងទើបខ្ញុំទៅយកមកណា ដល់អាពតចេញហើយនិងណាំ អាពតបែកហើយ និងណា បានខ្ញុំយកមកបានវាមកតាមណាៗ ខ្ញុំយកម្តាយខ្ញុំមក វាមកតាមមក ឪពុក ខ្ញុំគេយកបាត់ទៅទើបខ្ញុំយកម្តាយខ្ញុំមក ដល់បែកនិងហេះ ខ្ញុំអាណិតគាត់ពេក គាត់នៅ ជាមួយគ្នា ខ្ញុំយកមកម ដល់ហើយយកមកគាត់ឈឺ គាត់ឈឺនិងក៏មិនមែនឈឺអីដែរ អូន ឈឺនិងអត់ដែរនិងណាំ គាត់រត់ទៅដល់ឯភ្នំលះបង់អីណោះ

កល្យាន: គាត់រត់ទៅដល់ភ្នំលះបង់?

ហាន: ចាំ រត់បែកខ្ញុំ ព្រោះខ្ញុំទៅនៅនេះ ហើយគាត់នៅភូមិត្រាំកក់ណោះ

សាវីណា: រត់កាលពី៧៩និង?

ហានៈ ចាំរត់កាលពីអាពតដេញនិង និងហើយ ភ្លំលះបង់ឆ្ងាយណាស់ណាំ ទៅដល់លះបង់កូនខ្ញុំថាគេឲ្យកាន់អាខ្សែព្ជួរអញ្ចឹងឆ្លងទៅថៃណា វាថា វាអត់ឆ្លងចោលយាយវាទេ វាថាបើយាយវាទៅរួចទើបវាទៅ បើយាយវាអត់ទៅ វាអត់ទៅទេ លះបង់និងវាចោលតាំងពីគោ ចោលអី ដឹកទៅវាចោលអស់រលីងអូន មកតែខ្លួនទទេទេកូនខ្ញុំ ហើយគ្មានបាយហូបទេអូនឯង ទៅនៅនិងអត់មានបាយហូបទេ ហើយខ្ញុំរត់ទៅដល់ពោធិសង្សដែរនិង នៅឃុំតាភេមនិង ខ្ញុំទៅដល់ឆ្ងាយដែរនិងណា ហើយទៅដល់និងដឹកស្រូវពីខ្នារនេះយកទៅហូបហេះ កន្លែងនេះនិង ឡានហេះគេរពើលើអញ្ចឹងអូនណាំ ឡានហេះទាហានយើងនិងណាំ ហើយដឹកេកាលនិងត្រឹមខ្នារមកកើតអពោះដីខាងទាហានណាអូនដីទៅអញ្ចឹងនិងខាងគេរំដោះហើយ ហើយមកអញ្ចឹងយប់រទេះបាក់អីអញ្ចឹងទៅ បានចូលទៅដល់ដីអាពតនិងដេកលែងអីទៅណាអូន បើនៅខាងនេះខ្លាចឡានហេះ

សាវីណាៈ អញ្ចឹងអ៊ីនិយាយតទៀតទៅ?

ហានៈ អញ្ចឹងបានជាខ្ញុំរត់ទៅនោះនិងណាអូន ដឹកស្រូវយកហូបដល់ហើយ កាលនេះអាពតគេនៅខាងនោះនិង គេឲ្យខ្ញុំរត់ទៅភ្នំលិចណា ខ្ញុំមិនទៅណា ខ្ញុំសុខចិត្តរត់មកខាងណេះវិញហេះ

កល្យានៈ ៧៩ ហេះអ៊ី?

ហានៈ ចាំ កាលនិងយួនចូលមកហើយ កាលនិងយៀកណាមចូល ហើយបាញ់ប្តីយាយសុន និងយាយសុននិងអាពតគេវ៉ៃចោលនិង គេបាញ់ចោលដែរនិង ហើយខ្ញុំមកនេះមក គេថាទៅនិងកុំភ្លេចធាតុដើមណា បានសារុងកុំភ្លេចសំពត់ខ្មៅណា

សាវីណាៈ នរណាគេថា?

ហានៈ មេអាពតនិង គណៈកងគេនិងណា តាហ៊ុននិង ចាំគេថា បើទៅនិងបើបានសារុងស្លៀកកុំភ្លេចខោអាវសំពត់ខ្មៅគេ ឲ្យនៅនឹកគេផង ហើយយាយសុននិងថាចាំខ្ញុំនឹក ៗ តែយប់និងអូន ទទួលពួកនិងបានចេញណា បើកុំចេញគេរើសពួកខ្ញុំនិងទៅវ៉ៃចោលអស់ ណាវ៉ៃទាំងពួកស្នាក់នៅនិងទាំងប៉ុន្មានគេរើសយកទៅតាមដាន យប់ឡើងអូនអើយគ្មានហ៊ានដេកទេ មិនហ៊ានសំរានទេ

Cassette 1
Side B

ហាន៖ ………មករទេះ មកខុសផ្លូវ ផ្លូវនិងវៀតណាមចុះរំដោះដល់ខាងលិចថ្នល់និងហើយ ហើយខ្ញុំមកបានចូលមកអញ្ចឹងទៅ ចូលព្រៃសណ្ដែកទៅ បានរត់ទៅតាមវៀតណាម កាលនិងវៀតណាមចូលខេត្តតាកែវយើងម្ដងណាអូន ហើយដកវិញ

កល្យាន៖ ឆ្នាំណាអ៊ីដែលចូលហើយដកវិញនិង?

ហាន៖ អត់ទេ ដកបានតែប៉ុន្មានខែទេអូនទើបចុះមកម្ដងទៀតណា៎

សាវីណា៖ ចុះចូលមកម្ដងហើយ ដក់ទៅវិញ មកម្ដងទៀតវៃបានមែនទេនតែម្ដង?

ហាន៖ និងហើយ តែមុនដំបូងអូនឯងមកអញ្ចឹងខ្ញុំនៅកន្ទែងភូមិត្រាំណោះ ពេលគេវៃណាៗ ភូមិត្រាំនិងអូនអើយ ភ័យគ្មាន អានិងគ្មានព្រលឹងទេ

សាវីណា៖ ឃុំអី?

ហាន៖ ភូមិត្រាំខាងត្បូងតាកែវនិង ឃុំរការក្រោ ស្រុកដូនកែវ

សាវីណា៖ កាលនិងអ៊ុំទៅនិង?

ហាន៖ ខ្ញុំរត់បរទេះគោហើយទៅស្នាក់នៅនិង រត់ចូលមកអញ្ចឹងអត់ព្រមតាមគេទៅលិច ហើយគេដេញបាញ់ណាអូន គេដេញបាញ់ ហើយកាលនិងជន្ទងខ្ញុំនេះមានគោអាសរធំៗណា៎ គោនិងសំរាប់ដឹកស្បៀងពេលនៅអាពតនិងណា៎ ដឹកឲ្យដូចថា កងពិសេសខ្ញុំទៅនៅកន្ទែងណា គាត់ដឹងបាយបាយសំលរទៅឲ្យ ដឹកយកទៅឲ្យយើងហូបធ្វើការនិងណា ហើយវាឃើញអាគោសនិង មិត្តបងអើយត្រលប់មកក្រោយវិញមិត្តបង កុំទៅតាមយួនៗ គាត់ថាអញ្ចឹងណា៎ សំលេងឲ្យច្បាស់ចែស ខ្ញុំពរកូនខ្ញុំមីងតូចនិងហេះ ពរមីងនិងរត់អូនអើយ យាយចាស់មួយម្ដាយរបស់ជន្ទងខ្ញុំនិងខ្ញុំពរក្នុងប្រឡាយនិងអត់មានធូន់ទេអូន ដល់តែពេលបាត់ភ័យរត់អត់រួចផង មែនតើ រត់កាត់ផុកណាអូន រត់តាមប្រឡាយរត់រួច ដល់ពេលដាក់គាត់ចុះហើយ បាត់ភ័យរត់អត់រួច លើកអត់រួចសោះ កាលនិងអំណាចនិងភ័យអូន ខ្ញុំថាពរមីងនឹករត់ដល់ខាងកើតព្រៃសណ្ដែកអូន ខ្ញុំដល់ព្រៃសណ្ដែកណា កាលនិងវៀតណាមវារត់តាមផង ហើយគេដេញបាញ់រហូតដល់ កើតដល់បាំងថ្នល់ជាតិតើ បានវាឈប់បាញ់ខ្ញុំណា ដល់មកដល់ព្រៃសណ្ដែកនិង អានិងចោលរទេះចោលគោអីខ្ទេចអូន នៅភូមិត្រាំនិង និងវាបាញ់ចោលនិងអស់ហើយ ដល់វាទៅដល់នោះអាណិតកូនណាស់អូនអើយ យប់ឡើងអញ្ចឹងវារងាររដង រលឹមសស្រេចទឹកភ្លៀងណា ទៅដល់ភូមិគេនិងយកអាស្លឹកត្នោតនិងក្រាលឲ្យកូន នៅសល់តែក្រមាមួយគត់ ខោអាវអាសំពាវខោអាវចោលនៅភូមិត្រាំអស់ ទៅបានតែក្រមាមួយទេ ដណ្ដប់ឲ្យកូនយប់ឡើងដេក ដល់ពេកដេកនិងអ្នកស្រុកនិងគេឲ្យកិនអង្ករ កិន

ដាក់ស្បោងអញ្ចឹង រត់មកវិញមក ឡើងមកវិញណា ។ ឡើងមក នៅនិងបាន២យប់ ឡើងមកវិញនិងវៀតណាមទៅបាត់អស់ហើយ ទៅនោះបាត់អស់ហើយ ឡើងមកចូលដីអាពតវិញ

សាវីណា: ពេលដែលវៀតណាមវៃចូលហើយទៅវិញនិងហេះ?

ហាន: ចា៎ គេទៅអស់ហើយ បើទៅតាមគេមិនដឹងជាចូលដល់ណាណាអូន ត្រលប់មកវិញនិង កុហកគេថា មកដល់ឃើញគេវៃកប់ក្រសាំងៗនៅខាងត្បូងផ្សាគាកែវយើងនិង កប់អូនឯងអត់លេចដើងទេ តំបន់ពណ៌សាច់ប៉ុនៗនិងដើងនៅត្រឹមៗនិងគេគ្រាន់តែកាយកប់ៗបន្តិច នៅនិង មកដល់និងចូលដល់កន្លែងដែលយើងរត់និង បានអាសាក់កាដូនិងរទេះគោនិង ហើយមានដែលចងនៅលើនិងហើរភិលៗនៅនិង អូនឯងដឹកអានិងទៅ បានរទេះនិងដាក់អង្កទៅហូបទៅពោធិសង្ស ។ ប្រមូលស្រូវពីនេះយកទៅទុកនៅនិង ទុកនៅនិង ដល់ពេលបានស្រូវហើយផ្ញើអ្នកស្រុកនិងទើបរត់មក

សាវីណា: រត់មកនេះវិញ?

ហាន: រត់មកនៅនេះរហូត លែងអីរហូតទៅណាអូន

កល្យាន: អញ្ចឹងតាហ៊ិនថាបានសារុកកុំភ្លេចសំពត់និយាយនៅពោធិសង្សណោះទេ?

ហាន: នៅពោធិសង្សនិងណាអូន

កល្យាន: តាហ៊ិននិងហេះដែលជាអ្នកយកប្ដីអ៊ុំទៅ?

ហាន: អត់ទេ និងតានិងប្រធានភូមិ យកប្ដីខ្ញុំនិងតានៅណា៎ ។ តែដំណាងកងភូមិនេះគាត់គាដឹមនៅនេះដដែលទេ តែគាត់អត់ដឹងទេណា ដូចថាគាត់មកវាក្រោមបង្គាប់គេណា គេនិងប្រធានឃុំ គេមកដល់ឃើញប្ដីខ្ញុំគេមកឲ្យយកទៅ

កល្យាន: តានៅនិងគាត់ស្គាល់អ៊ុំតាំងពីត្រាំកក់ណោះនេះ?

ហាន: តាំងពីត្រាំកក់មក រៀនជាមួយគ្នាទៀតណាអូន នៅរៀនជាមួយគ្នា

កល្យាន: ចុះហេតុអីបានជាគាត់អត់យោគយល់អ៊ុំ គាត់យកទាំងប្ដីអ៊ុំទៀត?

ហាន: កាលនិងគេស្រលាញ់ខ្ញុំ ទៅនិយាយជាមួយឪពុកខ្ញុំតែគាត់មិនឲ្យទៅគេណា៎ អូនឯងកាលនិងអានៅនិងជាអ្នកក្រណា វាមិនមែនជាអ្នកមានទេ ហើយវាឃើញគ្រួសារខ្ញុំនិងវាគួរសម គេហៅថាគ្រួសារមូលធនណាអូន គ្រួសារខ្ញុំនិយាយទៅទាំងពូជ ឪពុកខ្ញុំគេយកអស់ ប្រុសៗគ្មាននៅទេ

កល្យាន: អញ្ចឹងនៅនិងជាអ្នកយកឪពុកអ៊ុំទៅដែរ?

ហាន: ចា៎ ឪពុកខ្ញុំនៅណោះ គេយកពីណោះមក ទៅក្រាំងតាចាន់និងតែម្ដង

កល្យាន: តានៅនិងកាន់នៅត្រាំកក់តែម្តង?

ហាន: កាន់នៅត្រាំកក់និងម៉ង

កល្យាន: គាត់យកឪពុកអ៊ុំនិងប្អូនអ៊ុំទៅសម្លាប់ទៅ?

ហាន: មិនដឹងជានៅនិងយក ឬអាប៉េះណាយកទេ ខ្ញុំអត់ដឹងដែរអានិងណា តែឥឡូវនិងវា យកនៅត្រាំកក់និង តែគេយកឪពុកខ្ញុំហើយទើបវាយកគ្រួសារខ្ញុំក្រោយនេះទេ

កល្យាន: ដល់អ៊ុំទៅនៅវត្តខ្នារនិង នៅនិងទៅកាន់នៅណោះដែរ?

ហាន: ចា៎

កល្យាន: ទៅតាមរករឿងអ៊ុំនៅនិងទៀត?

ហាន: ទៅរករឿងតាមដានខ្ញុំនៅនិងទៀត ខ្ញុំនៅវត្តខ្នារណាអូន ខ្ញុំប្រូតណា៎ គេឲ្យខ្ញុំបោកស្រូវ ខ្ញុំប្រូវបានមួយថ្ងៃ ប្រូតមួយថ្ងៃអញ្ចឹងវាដើរតាមខ្ញុំអញ្ចឹង វាដើររើសកគួរណាអូន វា រើសបានករគួរមួយ ដល់ហើយខ្ញុំនឹកឃើញខ្លួនខ្ញុំហើយ នឹកឃើញថា អាប៉េះនិងមុខជា មកតាមដានខ្ញុំហើយ ខ្ញុំនឹកអញ្ចឹង វារើសបានករគួមួយ យប់ឡើងប្រជុំម៉ងអូន ប្រជុំ វាថា ករគួរមិត្តយើងប្រូតទាំងអស់និងមើល កុំឲ្យវាជ្រុះ ជ្រុះមួយគួរនិងវាប៉ុន្មានគ្រាប់ ហើយមួយគ្រាប់និងវាចេញបានប៉ុន្មានដើម វានិយាយអញ្ចឹងណាអូន ខ្ញុំនឹកឃើញខ្ញុំ ភ័យទៀតហើយ ខ្ញុំនឹកថា យី! អានិងតាមដានខ្ញុំណាស់ ដល់ហើយខ្ញុំអត់មាត់ទេណា អូន វាលើកមកប្រជុំណា ប្រជុំពេលយប់ណា ដល់ហើយស្អែកឡើងគេឲ្យខ្ញុំចូលបោក ស្រូវហើយ គេឲ្យខ្ញុំបោកម្តង ខ្ញុំដើរបោកជាមួយគេ ខ្ញុំខ្ជិលមាត់អីក៏ដោយ ខ្ញុំខាំមាត់ ប៉ុណ្ណឹងព្រោះអីខ្លាចគេយកខ្ញុំទៀត នឹកឃើញអាណិតកូនណា៎ កូនវានៅកំព្រា នឹក ឃើញអាណិតកូន ម្ល៉ោះហើយវាចេះតែនៅនិងទៅ កាលនិងគេលែងគិតកូនគិតចៅ ហើយអូន មានកូន កូននៅដោយកូន ឯងនៅដោយឯងទៅ

កល្យាន: អញ្ចឹងកូននៅតូចៗ៣និងនៅធ្នង់រលើងណោះទេ?

ហាន: នៅ៤

កល្យាន: តែកូនដែលនៅមណ្ឌលកុមារណា នៅធ្នង់រលើងណោះហេះ?

ហាន: កាលនៅត្រពាំងត្រាច វានៅកុមារត្រពាំងត្រាចនិង តែមីធំគេយកទៅនៅវត្តខ្នារ ធំ បន្តិចគេយកទៅចូលកងកុមារអីគេនោះ

កល្យាន: ចុះដែលអ៊ុំទៅវត្តខ្នារ កូនតូចៗ៣និងទៅដែរអត់?

ហាន: ទៅ ដល់ទៅនៅណោះគេឲ្យទៅ ឲ្យទៅ ប្រធានគេនៅនិងទៀត ប្រធានកុមារគេនៅនិង

សាវីណា: អញ្ចឹងនៅកងកុមារគេរហូត?

ហានៈ ចាំ នៅកងកុមាររហូត អត់មាននៅជាមួយខ្ញុំទេ យប់ឡើងទើបអាតូចៗនិងមកដេក អាធំនិងនៅដេកសង្កើចខាំនិង នៅកងគេមីធំនិងហេះ ហើយតាំងពីនិងមក ខ្ញុំចេញពីនិងមកទៅនៅនិងទៅ នៅនិងរហូត នៅជាមួយប្អូនទាល់តែបែក ដល់បែកនិងរត់ពីនិងតើអូន

កល្យានៈ រត់ពីខ្នារនិងទៅតាមគេនិងទៅ?

ហានៈ ចាំ រត់ពីខ្នារនិងទៅនោះម៉ង រត់ទៅលិចម៉ង អានិងដល់វៀតណាមចូលណាអូន ដល់ហើយរត់ចុះរត់ឡើងទៅដល់លិចនិង ខ្ញុំឈប់រត់ទៅ រត់មកដល់នេះ គេដេញទៅលិចខ្ញុំមិនទៅ

កល្យានៈ ចុះពេលអ៊ុំទៅលិចនិង ពេលដែលអ៊ុំចង់បកមកវិញនិង តាហ៊ិននិងអត់រកវ៉ៃរកបាញ់អីទេហេះ?

ហានៈ អត់ទេ គេគ្រាន់ថាអញ្ចេះ ហកឥឡូវទៅលិចទៀត ដល់ខ្ញុំលឺកាំភ្លើងណោះហើយខ្ញុំជាមួយជនួងខ្ញុំអីខ្ញុំថា អ៊ុំអើយអ៊ុំខ្ញុំមកនេះខ្ញុំថាកុំឲ្យវាមានកុំឲ្យបាញ់គ្នានិងណាអ៊ុំ រត់គេចគ្រាប់ រកកន្លែងសុខ ហើយឥឡូវគេលឺសូកាំភ្លើងនិងហើយ ឲ្យខ្ញុំទៅមុិចនិងកើតអ៊ុំ ខ្ញុំទៅកើតវិញហើយ ខ្ញុំអត់ទៅនិងទេអ៊ុំ ខ្ញុំទៅទៅណោះហើយ គាត់ថាអើ តែអញ្ចឹងគេផ្ដាំខ្ញុំថាបើបានសារុងស្លៀកកុំភ្លេចសំពត់ខ្មៅនិងណាអូន កុំភ្លេចធាតុដើមគេ ធាតុដើមគេអានិងហើយ

កល្យានៈ តាហ៊ិននិងនៅរស់ទេឥឡូវអ៊ុំ?

ហានៈ ស្លាប់បាត់អស់ហើយ តានិង

សាវីណាៈ ចុះពេលគេយកឪពុកអ៊ុំទៅនិងណា អ៊ុំមានដឹងថាឪពុករបស់អ៊ុំខុសអីទេ?

ហានៈ អត់ដឹងផង

សាវីណាៈ តាហ៊ុននិងជាអ្នកយកទៅ?

ហានៈ អត់ទៅ នៅត្រាំកក់ណោះទេ

សាវីណាៈ អញ្ចឹងឪពុកអ៊ុំនឹងអ៊ុំអត់មានដឹងថាខុសអីទេ ពេលគេយកគាត់ទៅនិង?

ហានៈ ខ្ញុំអតដឹងខុសផង

កល្យានៈ គេយកគាត់នៅឆ្នាំណាអ៊ុំ?

ហានៈ ឆ្នាំ ៧៥ មុនគ្រួសារខ្ញុំមួយឆ្នាំ

កល្យានៈ ខែប៉ុន្មាន?

ហានៈ មិនដឹងខែប៉ុន្មានទេអូន អត់ចាំខែទេ ភ្លេចបាត់អស់ទៅហើយ យូរពេកហើយ

សាវីណា៖ នរណាគេប្រាប់អ៊ុំ?

ហាន៖ មានអាមួយនិងវាទៅពីទាហានណាអូន វាចូលមកធ្វើទាហានណ៎ ដល់ហើយវារត់ទៅនិងណា ដល់គេដាក់គុកវា ត្រជៀកវានិងដផ្ដាប់មូលហើមៗប៉ុណ្ណណី ដល់ហើយដល់ពេលបាយគេយកបាយឲ្យវាស៊ីណា ស្លាបព្រាវាកាវប្រហោងរន្ធគុកនិងណា ដល់ហើយវារត់រួចមក រួចហើមត្រជៀកនិងប៉ុនៗនិងហេះ ហើយយកមកអានិងវាត្រូវជាក្មួយខ្ញុំដែរ ហើយវាមកប្រាប់ថា មីងអើយកុំទៅនោះណា ទៅនិងមិនបានទេ មើលត្រជៀកខ្ញុំហើមហើយ សុំថ្នាំពេទ្យគេឲ្យលែបទំរាំតែជាអូន មូលដផ្ដាប់ម៉ង

កល្យាន៖ គុកនៅឯណា?

ហាន៖ គុកនៅស្រុកត្រាំកក់និង

សាវីណា៖ ក្រាំងតាចាន់និងហេះ?

ហាន៖ មិនដឹងជាវាជាប់គុកអីទេ តែគេថាមួលវាហើយវាកាយគុកចេញតែម្តង មកប្រាប់ថាអ៊ុំគេយកទាទៅបាត់ហើយ

សាវីណា៖ អញ្ចឹងឪពុករបស់អ៊ុំនិងគាត់យកទៅដាក់គុកនិងដែរ?

ហាន៖ ឪពុកខ្ញុំគេយកទៅដាក់នៅក្រាំងតាចាន់ និងលឺពូដែលជួបគុកជាមួយគ្នា កូនគាត់មកនៅនេះណ៎ គាត់ថាស្គាល់ឪពុកខ្ញុំច្បាស់ណាស់ព្រោះឪពុកខ្ញុំគាត់ធ្វើអាចារ្យវត្តណា គាត់ថាគាត់ស្គាល់ច្បាស់ណាស់ សុំថ្នាំគេដក់ទៀត តែដល់ថ្ងៃនិងគេថាឪពុកខ្ញុំនិងគេយកឲ្យរួចខ្លួនណាអូន ហើយនៅក្រាំងតាចាន់និងអញ្ចឹងគេថា យកចេញរួចខ្លួននិងងាប់ហើយយកមកបាញ់ចោល យកមកវៃចោលហើយ គេថាអញ្ចឹងតែម្តង នៅនិងអញ្ចឹងតែ ម្តងហើយបើសិនជាយើងនៅជាប់និងអត់អីទេ ជាប់នៅធ្វើការនិងអត់អីទេ ពូដែលដែលឃើញពុកខ្ញុំនិងរួចខ្លួនណ៎

កល្យាន៖ គាត់ឈ្មោះអី?

ហាន៖ មិនដឹងជាឈ្មោះអីទេ គាត់រួចខ្លួនវិញណា

សាវីណា៖ គាត់នៅរស់ដល់សព្វថ្ងៃទេអ៊ុំ?

ហាន៖ គាត់ដូចជាស្លាប់ហើយយូរហើយ គាត់ប្រាប់ខ្ញុំអញ្ចឹង គាត់ប្រាប់ថា ឪពុកឯងនៅក្រាំងតាចាន់ហើយ គាត់ស្គាល់ណាស់ ព្រោះឪពុកខ្ញុំនិងម៉ាជីនិងទៅក្រាំងតាចាន់និងទៅអន្លង់រលាយទៅ ភូមិថ្មីអន្លង់រលាយនិង ស្គាល់គាត់ទាំងអស់ព្រោះគាត់ធ្វើអាចារ្យវត្តគាត់ដើរកាន់ពាលាការគេធ្វើអាចារ្យនោះ ម្លោះហើយគាត់ស្គាល់គ្នាទចន្លោះនរណាទេតានៅអីនិងសុទ្ធឪពុកខ្ញុំគាត់ការឲ្យតើ តែដល់គេយកមិនដឹងជាធ្វើម៉ិច?

កល្យាន: ហើយទៅនិងគេចាប់តែឪពុកអ៊ុំយកទៅ ឬមួយគេយកទាំងប្អូនៗទៅផង?

ហាន: ទេ យកតែឪពុកខ្ញុំទេ

កល្យាន: ចុះប្អូនៗ?

ហាន: ប្អូនៈស្លាប់ពេលក្រោយនិង

កល្យាន: ក្រោយនិងទេ គេយកទៅដែរ?

ហាន: ចាំ ហើយអាប្អូនថ្ងៃអីក៏ក្រោយដែរ ហើយបើប្ដីខ្ញុំនិងក្រោយគេហើយ

សាវីណា: ក្រោយគេ?

ហាន: ចាំ ប្ដីខ្ញុំនិងក្រោយគេ គេយកមកតាមខ្សែ

កល្យាន: ប្ដីអ៊ុំនិងប្រហែលជាខែណាគេយកនិង?

ហាន: ប្ដីខ្ញុំមិនដឹងជាខែអីទេ កំពុងតែវែកកណ្ដាប់អូន

កល្យាន: អញ្ចឹងប្រហែលជាខ្ទង់ខែ១០ ១១អីអញ្ចឹងមើលទៅ?

ហាន: ចាំ ខែ ១០ ខែ១១ អីនិង យើងកំពុងច្រូតកាលនិង

កល្យាន: ចុះអ៊ុំសំសួរយើងប្អូនស្រីម្នាក់ដែលថាខ្ចប់បាយហើយ ដែលថាបាយខ្ចប់អាចម៍ជ្រូកអី និង ចុះដល់ពេលថាអញ្ចឹង គេយកទៅទាំងពូជទាំងកូនអីហេះ?

ហាន: គេថាយើងប៉ងសម្លាប់គេ គេយកទាំងអស់អញ្ចឹងម៉ង

កល្យាន: បាយនិងខ្ចប់ឲ្យកងទព្ទ ឬខ្ចប់ឲ្យកងចល័ត?

ហាន: ខ្ចប់ឲ្យកងទព្ទគេនិងណាំ គេឲ្យខ្ចប់ឲ្យកងទព្ទគេហើយដាក់ឈ្មោះនៅនិងទៅ ដូចថាខ្ញុំ ឈ្មោះអីដាក់ឈ្មោះខ្ញុំអញ្ចឹងទៅ ហើយដល់ពេលអានិងមិនដឹងនរណាខូច នរណាគេ ស្អប់យើង យកម្ហូបនិងចេញគេដាក់អានោះមិនដឹង ឬមួយគេដាក់អញ្ចឹងតែគេចាប់ ថ្នាក់យើងម៉ងអូន គេចង់សម្លាប់យើងម៉ង

កល្យាន: ហើយកូនគាត់ប៉ុន្មាននាក់ដែលស្លាប់ជាមួយនិង?

ហាន: កូនមួយ ទើបតែកូនមុនដំបូង

សាវីណា: ស្រីឬប្រុស?

ហាន: កូនស្រីនៅតូចដែរនិង យកទៅទាំងអស់ម៉ង

កល្យាន: អាយុប៉ុន្មានកូនតូចនិង?

ហាន: កូននិងទើបប្រហែលជា១-២ឆ្នាំប៉ុណ្ណឹងទេ គេយកទៅទាំងអស់

កល្យាន: រួចដំណឹងឪពុក ឬប្អូននិង គេប្រាប់ក្រោយ៧៩ឬតាំងពីពេលនិងមក?

ហាន៖ មីប្អូនខ្ញុំនិងគេប្រាប់កាលជាមួយឪពុកខ្ញុំនិង គេលួចមកនិងគេប្រាប់ណា គេថាស្លាប់អស់ហើយ គេយកអស់ហើយគ្មាននៅទេ

កល្យាន៖ ចុះតាមួយដែលរួចពីក្រាំងតាចាន់ហើយមកប្រាប់អ៊ុំនិង គាត់ប្រាប់អ៊ុំក្រោយ៧៩ឬតាំងពី៧០ដាងនិងមក?

ហាន៖ អានេះគាត់ប្រាប់រួចហើយនិង

កល្យាន៖ អូ! ៧៩ហើយនិងហេះ?

ហាន៖ ចា៎

កល្យាន៖ អញ្ចឹងមុននិងអត់បានជួបគាត់ទេ?

ហាន៖ មុននិងអត់បានជួបទេ ព្រោះគេប្រាប់ខ្ញុំនិង បានខ្ញុំថាមិនដឹងជាឪពុកខ្ញុំគេយកទៅសម្លាប់ឯណានិងណា៎ ថាខ្ញុំឯងមុខជានៅក្រាំងតាចាន់ហើយ

កល្យាន៖ ឪពុកអ៊ុំឈ្មោះអីអ៊ុំ?

ហាន៖ ខ្ញុំពុកខ្ញុំឈ្មោះ អាំ វ៉ែន

សាវីណា៖ ចុះម្តាយ

ហាន៖ ម្តាយ អ៊ុក យុត

សាវីណា៖ កាលពីគាត់ស្លាប់ គាត់អាយុប៉ុន្មាន ឪពុក?

ហាន៖ ឪពុកស្លាប់ចាស់អីហើយណាអូន អាយុខ្ទង់៨០អីហើយ

សាវីណា៖ អូ! ចាស់ហើយ

ហាន៖ គាត់នៅធ្វើអាចារ្យវត្ត គាត់ចាស់តែនៅរឹងប៉ឹងដែរនិងណាអូន

សាវីណា៖ ចុះម្តាយ?

ហាន៖ ម្តាយប្អូនគាត់១០ឆ្នាំណោះ

កល្យាន៖ ចុះកូនប្រុសអ៊ុំដែលថាទៅជាមួយម្តាយអ៊ុំនោះ កាលពីឆ្នាំ៧៩គាត់អាយុប៉ុន្មាន?

ហាន៖ កូនប្រុសបងនិងហេះ?

សាវីណា៖ ចា៎

ហាន៖ កាលពី៧៩និងដល់ភ្នំលះបង់និងខ្ទង់អាយុ១៣អីនិង

សាវីណា៖ អញ្ចឹងបានន័យថាគាត់ទៅជាមួយយាយតែម្តង?

ហាន៖ ទៅជាមួយយាយតែម្តង

សាវីណា៖ គាត់ទៅតែពីរនាក់យាយទេហេះ?

ហាន៖ ទៅជាមួយយាយ ជាមួយបងខ្ញុំនិង ហើយវាមានគោវាមួយនឹមណាអូន វាដឹកទៅ ហើយដល់ភ្លំលះបង់និងចោលគោអីនិង វាយកយាយវាមកក្រោយវិញទៅ វាមកជាមួយបងខ្ញុំ បងខ្ញុំថាឲ្យទៅ វាថាខ្ញុំមិនទៅទេ ឈប់ទៅហើយ ខ្ញុំទៅក្រោយវិញ អ៊ីឯងទៅក៏ទៅចុះ ខ្ញុំមកក្រោយវិញហើយ ខ្ញុំមកដើរកាលនិងវៀតណាមទៅទាន់នៅនិងណា អូនទៅទាន់និងអូនអើយ ខ្លះគេដាក់បាយ គេទុកចោលម្ដាយនៅនិងទៅ គេទៅចោលតែគេទៅណាអូន ហើយគេថា ខ្ញុំធ្វើអញ្ចឹងទៅមិនកើត ខ្ញុំអត់ទៅចោលយាយខ្ញុំទេ ខ្ញុំទៅវិញហើយ ហើយបើតាមវាទៅវាទៅបានអូន តាមវាចេញទៅ វាកាន់គោនិងវាឆ្លងរួចហើយ តែវាអត់ទៅ ខ្ញុំមិនទៅចោលវាទេ សុខចិត្តនៅក្រោយវិញ

កល្យាន៖ ម្ដាយអ៊ីគាត់ចាស់ណាស់ហើយហេះ?

ហាន៖ ម្ដាយខ្ញុំគាត់ចាស់ហើយ ប្រហែលជាចាស់ជាងខ្ញុំ ចាស់ប្រហែលជាយាយមកអន្ទុយមិញនិង គាត់ទៅអត់រួច តែកាលនិងគេឲ្យគាត់ត្បាញនៅនេះណា នៅត្បាញសូត្រនិងត្បាញនៅរោងបាយណា គេឲ្យត្បាញក្រមាអីឲ្យគេ ចែកប្រជាជនអីនិង

សាវីណា៖ ចុះពេលឆ្នាំ ៧៩ ពេលគាត់ផ្ដាំថាកុំឲ្យទៅស្រុកនិង គាត់បានមកលេងនិងប្រាប់ឬគាត់ផ្ដាំតាមគេ?

ហាន៖ គាត់ផ្ដាំតាមគេមកនិងណា ផ្ដាំថាបើជួបខ្ញុំប្រាប់ថាកុំឲ្យទៅ ថាអញ្ចឹងណា ថាកុំឲ្យទៅប្រាប់អញ្ចឹងណា

សាវីណា៖ អញ្ចឹងបានន័យថា បានតែអ៊ីមួយទេពេលដែលចេញពីស្រុកនិងបាន?

ហាន៖ ចា៎ ខ្ញុំចេញពីស្រុកខ្ញុំបានតែខ្ញុំទេ មីប្អូនបងខ្ញុំនៅនិងទាំងអស់ តែបងប្អូនខ្ញុំនៅនោះគេសុទ្ធតែអ្នកមូលដ្ឋានណាអូន មានតែបងខ្ញុំមួយដែលមានប្រពន្ធឈ្មោះ ប៊ូ សាវីនិងគាត់ធ្វើគ្រូដែរ និងនៅចេញចូលមកក្នុងនេះតែ២នាក់ខ្ញុំនិងទេ ហើយនិងសុទ្ធតែអ្នកមូលដ្ឋានទាំងអស់ តែនៅតែគេសម្លាប់អូនឯងមើល

សាវីណា៖ ចុះប្អូនប្រុសអ៊ី២នាក់ដែលគេយកទៅនិង គាត់ធ្វើការអី?

ហាន៖ អត់មានប្អូនប្រុសទេ មានតែបង ។ គេយកគាត់ គាត់ជាទាហានជើងទឹក

សាវីណា៖ លន់ ណុលហេះ?

ហាន៖ ចា៎ ទាហានលន់ណុល

សាវីណា៖ ចុះមួយទៀត?

ហាន៖ មួយទៀតប្រុសមួយអត់ធ្វើអីផង មួយធ្វើគ្រូ ដែលនៅចូលមកក្នុងនេះមានតែ៣នាក់ទេណាអូន ចូលមកបានតែខ្ញុំហើយនិងបងខ្ញុំនិង ។ បងខ្ញុំដែលធ្វើចៅហ្វាយស្រុកនិង ណា៎

និងធ្វើគ្រូនិង តែកាលនិងគេឲ្យធ្វើចៅហ្វាយស្រុកនិងណា ទៅបរប៉ៃលិន ឲ្យទៅជំនាន់ក-៥និង គាត់ដាច់ជើងនៅនិងតើ

សាវីណាៈ គាត់ស្លាប់ឆ្នាំណា?

ហានៈ គាត់ទើបតែស្លាប់ជំនាន់យើងនេះតើអូន គាត់ស្លាប់ឆ្នាំទៅមួយនេះ

កល្យានៈ ហើយប្ដីអ៊ុំគាត់ធ្វើគ្រូដែរ?

ហានៈ ចា៎

កល្យានៈ បង្រៀននៅនិងវត្តឬនៅនិងសាលា?

ហានៈ បង្រៀននៅនិងសាលាវត្តឯកឧត្តមនិងសាលាត្រាំកក់និង ទៅធ្វើនៅវត្តឯកឧត្តមនិង ខាងលិចផ្សានិង

កល្យានៈ អ៊ុំសាករកនឹកមើល កាលពីគេយកប្ដីអ៊ុំទៅនិង ម៉ោងប៉ុន្មាន ហើយគាត់កំពុងធ្វើអី?

ហានៈ ម៉ោង ៩ ព្រឹក កំពុងរែកកណ្ដាប់និង

សាវីណាៈ ហើយអ៊ុំកំពង់ធ្វើអី?

ហានៈ ខ្ញុំកំពង់ស្ទោងដំឡូងនៅសហករណ៍និង កំពង់តែរែកកណ្ដាប់ផង ស្ទោងដំឡូងផង ដូចកណ្ដាប់និងគេរើសអញ្ចឹងមកគេយកមកចាក់ហើយយើងរើសដាក់ទៅ ហើយដល់បាត់និងទើបពូមួយដំណាងកងនេះ គាត់ស្រលាញ់គ្រួសារខ្ញុំណាស់ គាត់ខ្សឹបប្រាប់ថា តែមានឈ្លបគេមកអញ្ចឹង គេមកយកមនុស្សហើយណា៎

កល្យានៈ ចុះពេលនិងអ៊ុំឃើញគាត់មកក្រវែលទេ?

ហានៈ មកដែលនិងណាអូន

កល្យានៈ ប៉ុន្មាននាក់?

ហានៈ គេមក៣នាក់ គេអើតៗអញ្ចឹងណាអូន គេអើតហើយជួបប្រធានភូមិណា៎អូន គេកាន់កាំភ្លើងតែពីរដើមទេ គ្នាគេ៣នាក់

សាវីណាៈ គេមានសួរអ៊ុំរកដែរអត់?

ហានៈ គេអត់សួរទេ តែគ្រាន់តែអើតមើលអញ្ចឹង គេរកមើលគ្រួសារខ្ញុំនិងណា

សាវីណាៈ គ្រួសារធ្វើការជាមួយគ្នា គ្រាន់តែម្នាក់រែក ម្នាក់រៀប?

ហានៈ ចា៎ គាត់អ្នករែកពីវាលមក ខ្ញុំនៅកន្លែងភូមិនិងរៀប

សាវីណាៈ ចម្ងាយប៉ុន្មានពីកន្លែងវាលនិងកន្លែងអ៊ុំរៀប?

ហានៈ ប្រហែលជា១០ហិចតា អូន គាត់ទៅរែកក្បែរថ្នល់ត្បូងនេះណាអូន ហើយយកមកខ្ញុំនៅនិងរោងបាយគេនេះ

កល្យាន: ចម្ងាយអត់ដល់មួយគីឡូម៉ែត្រផងទេហេះ?

ហាន: ចាំ អត់ដល់ផង

កល្យាន: ហើយអញ្ចឹងគេប្រហែលជាគេទៅតាមនៅកន្លែងវែកនិង ហើយអ៊ុំអត់ដឹង?

ហាន: ចាំៈ គេតាមនៅនិង អត់ដឹងផង ហើយឌុបកង់កាលនិងណាអូន គេឲ្យយើងធាក់ គេកាន់កាំភ្លើងពីក្រោយណា គេឲ្យយើងធាក់ យកទៅ ដល់ហើយប្អូនខ្ញុំគាត់ថា គ្រួសារខ្ញុំនិងគេចាប់បាត់ហើយ អាប្អូនខ្ញុំនិងគេតាមទៅណា គេតាមទៅមើលផុតកន្ទុយភ្នែកដល់ហើយខ្ញុំមកវិញទៅ

សាវីណា: ប្អូនរបស់អ៊ុំមួយណាមួយទៀតតាមមើល?

ហាន: ប្អូនថ្លៃនិង

សាវីណា: អូ! ប្អូនថ្លៃតាមមើលដែរ?

ហាន: ចាំ

សាវីណា: ហើយមកប្រាប់អ៊ុំទៅ?

ហាន: ចាំ មកប្រាប់ខ្ញុំ គេថាគេយកហើយទៅផុះទៅ មកកន្លែងនិង មកផុះកន្លែងនិង ហើយខ្ញុំមកផុះមក ខ្ញុំយំអើយ គេប្រាប់ថាកុំឲ្យយំ តែយំគេតាមជានយើងណា គេយកយើងទៀត ហើយខ្ញុំទ្រាំមិនបាន ខ្ញុំចេះតែយំទៅ កាលនិងខ្ញុំស្គម ស្គមមែនទេនទៅ ណាំ ហើយទៅកងនិង ឃើញអាក្អែកបូលមកឃើញក្អៀកមកយំ នឹកឃើញទៅស្រក់ទឹកភ្នែកៗ យ៉ាប់ណាស់អូនអើយ នឹកឃើញកាលនិងកំសត់កម្រចិញ្ចឹមកូនតាំងពីតូចៗវេទនាខ្លាំងណាស់ នៅជាមួយនេះនិង ហើយដល់ពេកបែកទៅរកស៊ីបានទិញម៉ាស៊ីនចាស់មួយ ម៉ាស៊ីនដេរនិងណា មាសម្តាយខ្ញុំនិងគាត់មុននិងទៅយកគាត់មកនិង នៅមាសគាត់មួយជីណាអូន គាត់ឲ្យមកហើយ ខ្ញុំយកមកទិញម៉ាស៊ីនដេរនិង យកមកដេរអាវដេរអីនិង ហើយយកអង្ករបានអង្ករបន្តិចបន្តួចអីអញ្ចឹងទៅចិញ្ចឹមកូន

កល្យាន: កាលពី៧៩និងហេះអ៊ុំ?

ហាន: ចាំ

កល្យាន: នរណាគេឲ្យមាសអ៊ុំ?

ហាន: ម្តាយខ្ញុំនិង

កល្យាន: អូ! គាត់លាក់មាសបានទៀត?

ហាន: គាត់នៅអាមាសដែលប្អូនខ្ញុំដែលស្លាប់និងណាំ ហើយគាត់ថាកូនឯងយកអានិងទៅ ទុកគ្រាន់ទិញស្អីៗរកស៊ីចិញ្ចឹមកូនណាំ ខ្ញុំនៅបានមាសមួយជីនិង ខ្ញុំមកកាលនិងទិញគោ

ដល់ហើយរកស៊ីទិញម៉ាស៊ីននិងដេរ ដេរអូនឯង ដេរនិងទុកគ្រាន់បានអន្តរចិញ្ចឹមកូន រហូតឲ្យរៀននិង បានមីមួយបានធ្វើគ្រូនិង ហើយអាបងខ្ញុំអត់បានធ្វើអ៊ីទេអូន កាលនិងប្រលងធ្វើគ្រូជាមួយគ្នាដែរ តែវាប្រលងអត់ជាប់ណាកាលនិង អត់បានធ្វើគ្រូ ធ្វើអីនិងទេ

កល្យាន: កូនមួយណាធ្វើគ្រូ?

ហាន: មីមួយអង្គុយកន្លែងនេះម៉ិញនិង

កល្យាន: កូនទីប៉ុន្មាន?

ហាន: កូននិងរៀនដល់ថ្នាក់ទី១១

កល្យាន: តែកូនទីប៉ុន្មាន?

ហាន: កូនទី៣

កល្យាន: ចុះកូនទី២ធ្វើអី?

ហាន: កូនទី២មីមួយនោះ វាធ្វើស្រែនិង ផ្ទះវានៅនិង

កល្យាន: ចុះនរណាដេរ?

ហាន: ដេរនិងមីនេះកូនទី៤ ហើយមីនិងវាស្នងរាជពីខ្ញុំ វានៅជាមួយខ្ញុំណាអូន ដល់ពេលខ្ញុំចាស់ទៅ ខ្ញុំអ្នកកាត់ វាអ្នកដេរ ខ្ញុំអ្នកកាត់អញ្ចឹងទៅ កាត់ឲ្យវាដេរអូនណា៎

សាវីណា: ឥឡូវនិងអ៊ីយល់ឃើញយ៉ាងម៉ិចដែរចំពោះរឿងរ៉ាវកាលពីជំនាន់និង?

ហាន: កាលពីជំនាន់និងវាហួសហេតុពេកហើយអូន វាឈឺចិត្តណាស់វាហួសនិយាយហើយអូនទាល់តែទៅឃើញអញ្ចឹងទៅ នឹកឃើញថាខ្លួនខ្ញុំមិនសមបានរស់មកប៉ុណ្ណឹងទេ វាចិញ្ចឹមកូននិងវាវេទនាពេកទៅណាអូន វាគ្មានឪពុកនិងគេ ហើយចិញ្ចឹមដោយយ៉ាប់យ៉ឺនមាំណាស់

សាវីណា: តាំងពីនិងមកអ៊ីអត់រៀបការម្តងទៀតទេហេះ?

ហាន: អត់ទេ គេនិយាយនិងខ្ញុំដែរ តែខ្ញុំមិនយកប្តីតែម្តង ខ្ញុំនឹកឃើញខ្លាចគេធ្វើបាបកូនហើយណាមួយយកប្តីខ្លាចគេធ្វើបាបទៅ ប្តីមុនប្តីក្រោយមិនបានដូចវិញណា ខ្ញុំមិនយកទេប្តី នឹកឃើញថា ចិញ្ចឹមកូនខ្ញុំឲ្យតែបានរស់ធំទៅ

សាវីណា: អ៊ីគិតថា រឿងរ៉ាវដែលបានឆ្លងកាត់ពីសម័យខ្មែរក្រហមនិង តើវាយុត្តិធម៌សំរាប់អ៊ីដែរអត់?

ហាន: គ្មានយុត្តិធម៌ទេអ៊ីអើយ យុត្តិធម៌អីបើវាធ្វើបាបម្ល៉ឹងៗហើយនេះ ធ្វើនេះធ្វើដូចជាគំនុំនរណាចងគំនុំគ្នាអី សម្លាប់យកតែម្តង អត់មានច្បាប់ទំលាប់អីទេ គេធ្វើនិងៗ

ហើយតាំងពីនិងមកអូនឯងស្គម ទឹកឃើញមក តាំងពីពេលដែលគេយកគាត់ទៅបាត់និងស្គម គេឲ្យទៅកងមួយថ្ងៃៗគ្មាននៅផ្ទះទេ មិនដែលនៅស្គាល់នៅផ្ទះយ៉ាងម៉ិចស្គាល់កូនយ៉ាងម៉ិចទេ តាំងពីពេលនិងមករហូតអូន

សាវីណា: ហូបបាយឬហូបបបរកាលនិងអូន?

ហាន: ហូបបបរ បបរល្មមៗព្រោះខ្ញុំកងមុខណា ខ្ញុំកងពិសេស កងពិសេសអញ្ចឹងគេអត់សូវឲ្យហូបរាវទេ ហើយខ្ញុំរែកណោះ គេធ្វើបាបមិនដឹង ខ្ញុំរែកនៅអូស្វាយចេកណោះណាអូន គ្នា៥នាក់រែក៣កាប់២ ជម្រៅចុះទៅក្រោម៤ម៉ែត ហើយអូនអើយហូបទឹកមិនដឹងចេញទៅណា អត់មាននោមទេ មួយថ្ងៃនិងអត់មាននោមតែម្តង ឡើងមកមួយអំរែកអញ្ចឹងហូបទឹក ឡើងហើយចោទអញ្ចឹងណាអូន កាប់ដីធ្វើគន្លាក់ៗចោទត្រង់អញ្ចឹងតែម្តង ឡើងមកដក់លើអញ្ចឹងណាអូន ម៉ាទោសទៅ ដូចយើងជាប់ទោសផងនឹតអញ្ចឹងក្តៅក្នុងនិ វាថាស្អុះនោះ ស្អុះ តែគេឲ្យធ្វើហើយ មិនដឹងធ្វើម៉ិចអូនអើយ មកវិញថាទំរាំតែហើយ៤ថ្ងៃនិងផ្តាំកូនផ្តាំចៅ

សាវីណា: ៤ថ្ងៃនិងប្រវែងម៉ាន?

ហាន: ៤ ម៉ែត្រ ហើយអាចេញមក៥ម៉ែត្រ ចែកគ្នាណា៎ ហើយជំរៅទៅក្រោយបួនម៉ែត្រហើយទទឹងប្រឡាយអញ្ចឹង៤ម៉ែត្រ ជ្រៅណាស់អូន ជ្រៅជាងផ្ទះនេះទៀត ហើយយ៉ាប់ណាស់ខ្ញុំ ខ្ញុំទៅនៅកង មិនដែលនៅផ្ទះទេ វានៅតែត្រពាំងត្រាចនិងទាំងអស់ ខ្ញុំមកផ្ទះយប់ៗនិង មកដល់ជួបកូនថ្ងៃ១០ ថ្ងៃ២០និងជួបម្តងៗអញ្ចឹងទៅ

សាវីណា: គេឲ្យអ៊ុំធ្វើការងារអីខ្លះអ៊ុំ?

ហាន: នៅនិងធ្វើស្រែប្រាំងទៅស្ទូង ទៅសន្ទ្ទំដី កើបអាចម៍យកទៅដីស្រែ ដូចថាគេឲ្យយើងមួយក្រឡាៗអញ្ចឹងស្រែប្រាំងណា៎ យកអាចម៍និងទៅបាចទៅ តែកាលនិងខ្ញុំចេះតែមានប្រាជ្ញាដែរ ខ្ញុំនៅសំកុកក្រោយគេយូរៗទើបចែវទូកទៅ ទូកត្នោតណាអូន ចែវមកកើបអាចម៍និង ខ្ញុំចេះតែមកក្រោយគេទៅ ខ្ញុំកើបអស់ទៅ អស់ទៅគេឲ្យខ្ញុំទៅកាប់កន្ទាងខែត្រ ហើយនិងត្រគាតយើងនិង ទៅដើរសន្ទ្ទំយកមកបាចទៅ ខ្ញុំចេះតែដើរធ្វើតាមគេអញ្ចឹងទៅ ឲ្យតែគេឲ្យធ្វើចេះតែធ្វើទៅ ហើយរោងកាលពីធ្វើតូចខ្ទនឯងអញ្ចឹងរោងតូចណាស់ ប៉ុណ្ណឹងដាក់សែងទៅ ទៅណាគេឲ្យដាក់សែងទៅតាមទៅ ខ្ញុំនៅតែងកស្មោះ អត់ដែលស្គាល់ផ្ទះនិងកូនយ៉ាងម៉ិចទេ វេទនាណាស់កាលនិង អត់ដែលស្គាល់កូនទេ គេធ្វើនិងចង់បំបាត់យើងកុំឲ្យស្គាល់កូនស្គាល់ចៅ ពិបាកយើងថែរក្សាគេថាគេមានថែរក្សាហើយ គេបំបាត់យើងមិនឲ្យស្គាល់កូនយើងទេ យើងដឹងតែយើង

ធ្វើការទៅ កុំគិតគូររឿងគេ បានខ្ញុំថាតាំងពីនិងមក ពេលដែលខ្ញុំនឹកឃើញរឿងអាពត និងមកអស់ហើយ គ្មានសល់អីបន្តិចទេ

កល្យាន: អ៊ុំខស្សារហ៍នឹកឃើញញឹកញាប់អត់?

ហាន: នឹកដែរនិងណាអូន អន្តុយលែង១ចេះតែនឹកឃើញដែរនិងណា

កល្យាន: ពេលនឹកឃើញម្តងខ្ញុំក្នុងចិត្តអ៊ុំយ៉ាងម៉ិចដែរ?

ហាន: នឹកឃើញម្តង១យំ នឹកឃើញយំណាស់អូន អន្តុយសំរក់ទឹកភ្នែកពេលគ្រាកំសត់ចិញ្ចឹមកូនណា៎

កល្យាន: ពេលណាដែលធ្វើឲ្យអ៊ុំនឹកឃើញជំនាន់អាពតឡើងវិញ?

ហាន: កាលណាដេកមិនលក់នឹកឃើញ នឹកគិតទៅដេកមិនលក់តែម្តង

កល្យាន: អញ្ចឹងអ៊ុំមានដែលធ្លាប់គិតថា ចង់សងសឹកជាមួយខ្មែរក្រហមទេ?

ហាន: ចង់សងសឹកចង់ពេកហើយ ទៅនៅនេះប៉ុន្មានដងនិងចង់សួរថា ចង់សងសឹក តែនឹកឃើញថា ប្រទេសជាតិយើងមានសិទ្ធមនុស្សអីអញ្ចឹងទៅ គេថា ធ្វើបាបគេ គេមានទោសណាអូន នឹកឃើញអញ្ចឹងទៅ ធ្វើម៉ិចបើគ្រួសារយើងស្លាប់បាត់ទៅហើយ វាយូរហើយ ខ្ញុំលែងនឹកឃើញសងឈាមហើយ ធ្វើម៉ិចបើគាត់ទៅហើយ ឲ្យគាត់ទៅចុះ

សាវីណា: បើគិតមកដល់ឥឡូវ អ៊ុំមានរសាយក្នុងចិត្តខ្លះទេ?

ហាន: ឥឡូវវារសាយខ្លះហើយអូន កាលណានេះទៅវា ខ្ញុំនឹកឃើញតែនេះទេ នឹកឃើញថាកូនខ្ញុំបើសិនជាឪពុកវានៅវាសប្បាយចិត្តណាស់ណា ដល់កូនព្រាត់ឪពុកអញ្ចឹង នឹកឃើញថាអណោចអធម៌ នឹកឃើញអាណិតកូនដែរនិងណា ហើយនឹកឃើញអាអ្នកធ្វើបាបកូនចៅខ្ញុំនិង ធ្វើបាបខ្ញុំ ឪពុកខ្ញុំនិង នឹកឃើញអន់ចិត្តដែរនិងណាអូន ខឹងដែរនិង

សាវីណា: ចុះបើឥឡូវនេះ គេមានតុលាការមួយដែលកាត់ទោសមេដឹកនាំខ្មែរក្រហម អ៊ុំធ្លាប់លឺតុលាការនិងទេអ៊ុំ?

ហាន: ដូចជាមិនដែលឃើញផងអូន

សាវីណា: គេធ្លាប់ផ្សាយតាមវិទ្យុ ទូរទស្សន៍អីដែរណា?

ហាន: អូ! គេកាត់ទោសខ្មែរក្រហមនិងហេះ?

សាវីណា: ចា៎

ហាន: អានិងកំហឹងឈឺចាប់ វាមានដែរនិងណាអូន

សាវីណា: អ៊ុំយល់យ៉ាងម៉ិចពីរឿងតុលាកានិងអ៊ុំ?

ហាន: តុលាការនិងអូនខ្ញុំថា គេត្រឹមត្រូវ.................

Cassette 2
Side A

ហានៈ ..........តាមគ្រាំចិត្តយើងនិងមានខ្លាំងពេកហើយណាអូន

សាវីណាៈ ចុះបើសិនជាឧបមាថាគេឲ្យអ៊ុំរើសរវាងសងសឹកផ្ទាល់ជាមួយអ្នកដែលធ្វើបាបប្តីអ៊ុំនិងយកអ្នកនិងទៅកាត់ទោស តើអ៊ុំរើសយកមួយណា?

ហានៈ យកទៅកាត់ទោសអូន កុំយកគេទៅកាត់ទោសព្រោះអីវាខុសច្បាប់ណាំ និងហើយ បើកាលណាគេកាត់ទោសទៅវាខុសហើយអូនណា អានិងគេថាយើងមានទោសដល់ថ្ងៃក្រោយទៀត ហើយបើគេយកទៅកាត់ទៅឲ្យច្បាប់ធ្វើតាមទោសវាទៅ និងហើយ

កល្យានៈ យើងយកគេទៅកាត់ទោសនិងគេហៅថាសងសឹកអីដែរអត់អ៊ុំ?

ហានៈ អានិងក៏សងសឹកដែរតែរកតាមច្បាប់អ៊ុំ តាមយុត្តិធម៌ និងហើយ រកយុត្តិធម៌

កល្យានៈ ចុះបើគេថាឥឡូវផ្សះផ្សាជាតិហើយ ឲ្យអ៊ុំឈប់ខឹងគេទៅ រស់នៅជាមួយគ្នា មិនបាច់កាត់ទោសទេ តើអ៊ុំព្រមអត់?

ហានៈ អានិងមានអីអូន យើងព្រមព្រាងធ្វើម៉ិចតាមស្រុកទេសអញ្ចឹងអូនណា

កល្យានៈ បើអ៊ុំព្រមតើក្នុងចិត្តអ៊ុំស្ងប់ដែរអត់?

ហានៈ បើខ្ញុំព្រមលះលែងតែក្នុងចិត្តអត់សូវស្ងប់ប៉ុន្មានទេ នៅរៀងខឹងដែរ នៅនឹកខឹងដែរណាអូនវាធ្វើបាបយើងណាស់តែធ្វើម៉ិចឥឡូវហើយឥឡូវក៏ខ្ញុំលែងនេះដែរ ខ្ញុំកាន់សិល្ប៍ កាន់ទានហើយ នឹកឃើញថា លែងសងសឹកគេហើយ ធ្វើម៉ិច លែងចងកំហឹងនិងគេហើយអូនណាំធ្វើម៉ិច

កល្យានៈ បើសិនជាមានការកាត់ទោស អ៊ុំចង់ឲ្យកាត់ទោសមេដឹកនាំប្រទេសឬក៏កាត់ទោសទាំងអ្នកក្រោមទៀតអ៊ុំ?

ហានៈ បើសិនកាត់ទោស អានិងមេដឹកនាំអាពតនិង អានិងគេកាត់ទោសមេដឹកនាំនិង វាមិនអាចទេបើវាច្រើនដែរអូន មកក្រោមមក

កល្យានៈ អញ្ចឹងអ៊ុំយល់ថាគួរតែកាត់ដែរអត់ថ្នាក់ក្រោមនិង?

ហានៈ ថ្នាក់ក្រោមនិងបើតាមត្រូវកាត់ ត្រូវកាត់ដែរ តែឥឡូវវាច្រើនណាស់ តគ្នាដូចខ្សែអញ្ចឹងរយើងរយោងដែរនិង

កល្យាន:	រាល់ថ្ងៃអ៊ុំសុំសិលប៉ុន្មានអ៊ុំ?

ហាន:	ខ្ញុំសុំសីល ៥

កល្យាន:	អញ្ចឹងខ្ញុំសួរអ៊ុំទាក់ទងនិងរឿងសីលវិញ ព្រះពុទ្ធលោកថាពារ៍រំងាប់ដោយការមិនចងពារ៍ អានិងមានន័យថាម៉ិចអ៊ុំ?

ហាន:	អានិងដូចថា យើងខឹងអីទៅ គេឲ្យយើងឈប់មានកំហឹងណាំ ថាលែងឲ្យមានកំហឹងឈឺចាប់អីដូចថាអានិងគេថារំសាយទៅ កុំឲ្យមានកំហឹងនិងទៅ អានិងដូចជាយើងបាបនិងណាអូន ដូចយើងប៉ងប្រាថ្នាគេនិងណាំ ចង់សម្លាប់គេអញ្ចឹងទៅ អានិងមានទោសហើយអូន

កល្យាន:	ពាក្យថាចងពារ៍ និង សងសឹក ដូចគ្នាអត់អ៊ុំ? ឧទាហរណ៍ថាឈ្មោះ ក និងសម្លាប់ប្តី អ៊ុំ ហើយអ៊ុំចងពារ៍គេ ធ្វើម៉ិចទើបដឹងថាអ៊ុំចងពារ៍គេ?

ហាន:	អានិងគំនុំចងពារ៍ចិត្តយើងចង់ចាំធ្វើទោសវាថ្ងៃណាមួយ

កល្យាន:	អញ្ចឹងអារឿងធ្វើទោសគេថ្ងៃណាមួយនិងគេហៅថាសងសឹកដែរអត់អានិង?

ហាន:	អានិងសងសឹកហើយ

កល្យាន:	អូ! អានិងបើពារ៍រំងាប់ដោយមិនចងពារ៍និងសងសឹក?

ហាន:	ចាំ

កល្យាន:	ចុះបើពារ៍រំងាប់ដោយការមិនចងពារ៍វិញ?

ហាន:	អានិងដូចថាយើងមិនសងសឹកគេទេ ធ្វើម៉ិចបើស្រុកទេសទៅជាអញ្ចឹងហើយ ទៅជាអញ្ចឹងទៅ

កល្យាន:	ចុះបើយើងយកអ្នកនិងទៅឲ្យតុលាការកាត់ទៅ អានិងយើងហៅថាយើងចងពារ៍គេឬអត់អ៊ុំ?

ហាន:	បើយើងអត់មានទៅ អានិងគេរកយុត្តិធម៌ ហើយបើយើងមានចងពារ៍អី រដ្ឋគេរកយុត្តិធម៌ឲ្យយើង ហើយបើយើងគុំគេម៉ង គេប្តឹងគេឲ្យមកចាប់ពីនិងទៅណា អានិងវាចងពារហើយអានិងយើងទៅចងពារ៍គេហើយ ប្តឹងគេយកទៅហើយ ទៅចាប់គេហើយ ហើយ បើសិនជាយើងមិនប្តឹងគេទៅ អានិងរដ្ឋគេយកទៅតាមនេះ អានិងមិនដឹងធ្វើម៉ិចទេ

កល្យាន:	គ្រាន់តែប្តឹងគេនិង អានិងគេហៅថាចងពារ៍ដែរអ៊ុំហេះ?

ហាន:	ចាំ អានិងយើងប្តឹងគេ យើងគំនុំគេហើយអានិង

កល្យាន:	អ៊ុំយល់ថារឿងខ្មែរក្រហម គួរតែខ្មែរយើងដោះស្រាយឬក៏ឲ្យអន្តជាតិមកដោះស្រាយ?

ហាន៖ ចាំឲ្យគេដោះស្រាយទៅអូន តាមខ្ញុំថា

កល្យាន៖ ហេតុអី?

ហាន៖ ឲ្យតែខ្មែរ ព្រោះខ្មែរវាឈ្មោះទាំងខ្មែរ

កល្យាន៖ អញ្ចឹងខ្មែរនិងខ្មែរឈ្លោះគ្នាគួរតែឲ្យខ្មែរនិងខ្មែរដោះស្រាយ?

ហាន៖ ចាំ ដោះស្រាយខ្លួនឯងទៅ ឲ្យគេមកដោះស្រាយធ្វើអីទេ អានិងខ្ញាស់ស្រុកគេ ខ្មែរឯង ធ្វើតែខ្មែរឯង

កល្យាន៖ អ៊ុំយល់ពាក្យផ្សះផ្សាមានន័យថាម៉ិចទេអ៊ុំ?

ហាន៖ ផ្សះផ្សាគឺបង្រួបបង្រួមគ្នា យើងធ្វើឲ្យត្រជាក់ចិត្ត ឈប់ខឹងនិងគ្នាទៅណាអូន

កល្យាន៖ ចុះឈប់ខឹងម៉ិច ឧទាហរណ៍ថាផ្ទះអ៊ុំនៅនិង ហើយស្រាប់តែអ្នកដែលសម្លាប់ប្តីអ៊ុំផ្ទះ គាត់ នៅនោះ ទល់មុខនោះ ហើយគេឲ្យអ៊ុំ២នាក់និងផ្សះផ្សាគ្នា អ៊ុំព្រមអត់?

ហាន៖ បើសម្លាប់ហើយឲ្យផ្សះផ្សាគ្នា បើនៅថ្មីៗអាចនេះដែរនិងណាអូន ដូចថាវានៅខឹងណា តែ ដល់ពេលយូរទៅនិងវាចេះតែរសាយចិត្តហើយធ្វើម៉ិច

កល្យាន៖ ទោះជាអ្នកនិងអត់បានមកសុំទោសអូនក៏ដោយ?

ហាន៖ ចាំ បើគេសុំទោស សុំផ្សះផ្សាយើងទៅ យើងព្រមទៅ បើវានៅមានចងកំហឹង នៅមាន ថ្ងៃក្រោយទៅ អានិងខឹងដែរនិងណាអូន ធ្វើម៉ិចមិនឲ្យខឹងអានិង ដល់តែខឹង អញ្ចឹងដែរនិងណា

កល្យាន៖ ឧបមាថាគេមានកូនតូចៗ ហើយគេមានកូនតូចៗដែរ តើអ៊ុំមានឃាត់កូនកុំឲ្យទៅលេង ជាមួយគេដែរអត់?

ហាន៖ អានិងមានអី ធម្មតាក្មេងក្រោយវាទាក់ទងគ្នាធ្វើម៉ិច

កល្យាន៖ តែចិត្តអ៊ុំតើអ៊ុំបណ្តោយឲ្យក្មេងៗសេពគប់គ្នាឬកុំឲ្យវាលេងព្រោះកូនគាត់សាហាវឃោ ឃៅអញ្ចឹងណា?

ហាន៖ អត់ទេ

កល្យាន៖ ហេតុអីបានជាអ៊ុំគិតអញ្ចឹង?

ហាន៖ គិតអញ្ចឹងព្រោះអានេះចាស់ៗនេះសម្លាប់គ្នានោះហើយ ហើយក្មេងៗមានដឹងអី កើត មកហើយ កើតមកក្រោយ អានិងយើងបង្រៀនវាឲ្យចេះសាមគ្គីគ្នា កុំឲ្យចេះសាហាវ ចេះស្អប់គ្នាទេ ដល់ពេលយើងប្រាប់អញ្ចឹងទៅ ក្មេងវាមិនអាចដឹងទេណាអូន មកអំពី ចាស់ប្រាប់ ចាស់ប្រាប់ទៅនាំតែខូចក្មេង យើងប្រាប់វាធ្វើអី អានេះវាមិនសងសឹក ដូចរឿងចិនទេ ចងពៀរទុកទេ សម្លាប់ព្រោះម្តាយ ព្រោះឪពុកនិងណា

កល្យាន៖ ចុះអ៊ីយល់ថា ពាក្យយុត្តិធម៌និងមានន័យថាម៉េច សំរាប់អ៊ី?

ហាន៖ យុត្តិធម៌អានិងរកខុសត្រូវអ៊ី យុត្តិធម៌អំពើល្អណាអូន សុចរិតល្អត្រឹមត្រូវ យុត្តិធម៌ហើយ មានស៊ីសំណូកម្នាង១អានិងវាអត់យុត្តិធម៌ទេ ដូចប្អូនឯងអញ្ជឹង ខ្ញុំទៅសូកប៉ាន់ឲ្យប្អូនឯងឲ្យឈ្នះខ្ញុំអញ្ជឹងទៅ អានិងមិនយុត្តិធម៌ទេ យុត្តិធម៌និងហៅថាត្រឹមត្រូវណា

កល្យាន៖ អ៊ីមានដែលនិយាយពីរឿងអាពតប្រាប់ចៅតូចៗទេអ៊ី?

ហាន៖ រឿងជំនាន់អាពតខ្ញុំនិយាយដែរនិងណាថា ចៅឯងគ្រប់គ្នាអត់ដឹងទេ កើតមកដឹងតែពីសប្បាយ ខ្ញុំមិនដែលនិយាយប្រាប់ថា រកស៊ីវេទនាអីទេ គ្រាន់តែថាពិបាករស់ណាចៅអើយកាលពីជំនាន់អាពតណាំ ចៅឯងមិនដឹងទេ កុំចង់ដឹងអីពិបាករស់នៅណា

កល្យាន៖ តែអ៊ីមិនដែលរៀបរាប់ថារឿងរ៉ាវនិងវាកើតយ៉ាងម៉េចទេហេះ?

ហាន៖ អត់ទេ អត់ដឹងទេ

កល្យាន៖ ហេតុអីក៏អ៊ីមិនដែលប្រាប់វា?

ហាន៖ ខ្ញុំមិនចង់ប្រាប់ទេ វាពិបាកពេកទៅណាអូន

កល្យាន៖ តើអ៊ីយល់ថាក្មេងៗគួរតែដឹងរឿងនិងឬក៏អត់អ៊ី?

ហាន៖ ក្មេងហេះ?

កល្យាន៖ ចាំ

ហាន៖ មិនសូវឲ្យវាដឹងទេអូន

កល្យាន៖ ហេតុអី?

ហាន៖ នាំតែខូចខួរក្បាលវា វាគិតច្រើនណាអូន នាំតែវាកើតទុកណា

កល្យាន៖ ចុះឧបមាថាវាអត់ដឹង ហើយថ្ងៃក្រោយរបបនិងកើតឡើងម្ដងទៀត អានិងវាយ៉ាងម៉េចទៅ?

ហាន៖ កើតឡើងនិងឲ្យវាឃើញនិងភ្នែកវាទៅអូន ដល់យើងនិយាយប្រាប់វាអញ្ជឹងនាំតែវាដូចថាស្មារតីវាខ្សោយទៅណាអូន ដូចជាគ្មានសប្បាយក្នុងចិត្ត ចេះតែនឹកឃើញព្រួយ

កល្យាន៖ ចុះបើធ្វើអញ្ជឹងទៅ បើឧបមាថារបបនិងវិលមកម្ដងទៀត វារិតតែវេទនាដូចជាអ៊ីទៀតហើយ?

ហាន៖ ចាំ អានិងវេទនា បើថាឃើញទៅធ្វើម៉េច បើយើងនិយាយប្រាប់ យើងគ្រាន់ប្រាប់ថាយើងកុំនឹសកូនអើយ ក្លាចវាកើតសង្គ្រាមនិងឡើងវិញណា ដូចមុនឡើងវិញទៅ វាវេទនាណាស់ ម្ដាយវេទនាណាស់ យាយវេទនាណាស់ មិនដូចសម័យក្រោយនេះទេ សម័យក្រោយកូនឯងអត់ទាន់ដឹងច្បាស់ទេណា ដឹងតែសប្បាយទេ

កល្យាន:	ក្រៅពីនិយាយជាមួយចៅ ជាមួយអ្នកជិតខាងពេលដែលជួបគ្នា អ៊ុំខស្សារហ៍រំលឹករឿងអាពតទេ?

ហាន:	ខ្ញុំអត់សូវដែលនិយាយផង

កល្យាន:	អត់សូវបានយថាធ្លាប់និយាយខ្លះ តែអត់សូវញឹក

ហាន:	និងហើយ ខ្ញុំមិនដែលសូវនិយាយផង នឹកឃើញថារបបនិងវាហួសហើយអូន វាហួសហើយ របបនិងវាហួសហើយ មិនចង់ឲ្យលឺដល់ទេ មិនចងឲ្យឃើញទេ

កល្យាន:	អញ្ចឹងអ៊ុំចង់បំភ្លេចរឿងនិងឬអត់?

ហាន:	ខ្ញុំរឿងអាពតនិង បើចៅក្រោយអត់ចង់ឲ្យដឹងទេអូន

កល្យាន:	តែខ្លួនអ៊ុំណា៎ អ៊ុំចង់ភ្លេចដែរអត់?

ហាន:	ខ្ញុំអត់ទាន់ភ្លេចទេ នៅចាំជាប់តែម្តង

កល្យាន:	តែអ៊ុំចង់ភ្លេចឬអត់ចង់

ហាន:	ខ្លួនឯង នៅអត់ភ្លេចទេ តែអត់ចង់ឲ្យឃើញ អត់ចង់នឹកឃើញអញ្ចឹងម្តងទៀតណា ថាវាធ្វើបុណ្យរាល់ថ្ងៃនិងថាលាកចាករបបនិងទៀតណាអូន ឲ្យវាសប្បាយអញ្ចឹងរហូតទៅកុំឲ្យមានអញ្ចឹងទៀតណា៎

កល្យាន:	ឧទាហរណ៍ថា អត់មាននរណារំលឹកអ៊ុំយូរឆ្នាំទៅ អ៊ុំគិតថា អ៊ុំអាចភ្លេចទៅទេ អ៊ុំអាចលែងនឹកនារឿងនិងទាំងអស់ទេ?

ហាន:	អត់ទេ ចាំជាប់ ចុះយើងធ្លាប់ពិបាកយូរមកហើយណាអូន អានិងដក់ខ្លួនយើងដូចមេរៀនអញ្ចឹង អក្សរអីអាចភ្លេចកើតណា៎អូន អានិងវាមិនភ្លេចម៉ង ដូចវាមិនភ្លេចម៉ង ដូចវានៅតែនឹកឃើញវេទនា នឹកឃើញលំបាកនិងណា ឃើញនៅជាប់និងម៉ង ដូចមេ រៀនអីឃើញអក្សរអីអាចភ្លេចខ្លះ

កល្យាន:	អញ្ចឹងអ៊ុំ ក្រៅពីអ្វីដែលខ្ញុំសួរ អ៊ុំមានអ៊ីចង់ប្រាប់ខ្ញុំទៀតទេអ៊ុំ?

ហាន:	ប្រាប់រឿងអី

កល្យាន:	ឥឡូវខ្ញុំអត់មានអីសួរអ៊ុំទៀតទេ តែអ៊ុំមានអ៊ីចង់សួរខ្ញុំទៀតអត់ មានចង់បញ្ចេញយោបល់អ្វីប្រាប់ខ្ញុំទៀតអត់? ចង់និយាយថាម៉ិចក៏បាន?

ហាន:	ចង់តែឲ្យស្រុកសប្បាយនិងណាអូន កុំឲ្យមានអ៊ីឈ្លោះគ្នាអីណា កុំឲ្យវាមានកើតអានិងឡើងវិញណាអូន បើកើតឡើងវិញវានាំតែពិបាកដល់ក្មេងជំនាន់ក្រោយណាអូន

សាវីណា:	ចុះអ៊ុំកាលពីជំនាន់អាពតនិង អ៊ុំមានដែលខ្វះខាតម្ហូបអាហារ ខ្វះទឹកអីអត់អ៊ុំ?

ហាន:	កាលពីអាពត ម្ហូបខ្វះណាស់អូនអើយ មិនដែលបានហូបឆ្អែតទេ

សាវីណាៈ ចុះមានដែលឃើញអ្នកផ្សេងគេខ្វះដូចអ៊ុំអីដែរអត់អ៊ុំ?

ហានៈ គេខ្វះដូចតែគ្នាអូន អត់ខ្វះតែគេមូលដ្ឋានទេ

សាវីណាៈ អញ្ចឹងធ្លាប់លឺនៅកន្លែងផ្សេងគេខ្វះដែរអត់អ៊ុំ?

ហានៈ កន្លែងផ្សេងខ្ញុំលឺគេថាខ្វះដូចតែគ្នាអូន មានតែខ្វះជាងខ្ញុំនិងផង

សាវីណាៈ ជំនាន់និងអ៊ុំដែលខ្វះខាតថ្នាំព្យាបាលដែរទេពេលដែលអ៊ុំឈឺអីនិង?

ហានៈ ខ្វះ អត់មានទេអូន គេឲ្យតែអីដូចអាចម៍ទន្សាយអញ្ចឹងណា៎ បើសុំគេទើបបាន ហើយបើឈឺ ខ្ញុំថ្ងោះខ្លួនម្ដង គេថាខ្ញុំឈឺសក្ដិអារម្មណ៍ណាអូន ថ្ងោះខ្លួនទល់និងឥឡូវណាអូនឥឡូវនិងចុកសរសៃ

កល្យានៈ ឆ្នាំណាអ៊ុំ?

ហានៈ កាលនិងខ្ញុំទៅធ្វើប្រឡាយនេះ ហើយខ្ញុំថ្ងោះខ្លួនណាអូន ខំប្រឹងលើកណា៎ ដល់ខ្ញុំថ្ងោះខ្លួនគេថាខ្ញុំនិងសក្ដិអារម្មណ៍ណា កាលនិងគេរករឿងខ្ញុំខ្លាំងដែរនិងណា ព្រោះអីគេយកប្ដីហើយដល់យើងអញ្ចឹងទៀត គេចង់យកយើងទៅ គេថាយើងនិងមាយាអីទៅ គេថាយើងមិនថ្ងោះខ្លួន វាជម្ងឺអត់ឃើញណា តែខ្ញុំឈឺនេះ ដល់ថ្នាក់លោតណា៎ ឈឺនៅតែចុកដើងមួយចំហៀង ដេកយប់ ដេកអត់បានទេ ចុកណាស់ ចុះថ្ងោះកាលនិងមានគ្រូឯណាមើល អត់មានគ្រូឯណាមើលទេ

សាវីណាៈ ចុះអ៊ុំមានឃើញអ្នកផ្សេងគេឈឺហើយអត់មានថ្នាំដែរទេ?

ហានៈ ឃើញដែរនិង មានអ្នកខ្វះស្លាប់ផងអូន

សាវីណាៈ ធ្លាប់លឺនៅកន្លែងផ្សេងទេអ៊ុំ?

ហានៈ លឺនៅនិងក៏មានដែរ ឈឺអត់មានអីមើល

សាវីណាៈ ចុះពេលអ៊ុំទៅកងចល័តអីអញ្ចឹង អ៊ុំមានកន្លែងស្នាក់គ្រប់គ្រាន់ទេអ៊ុំ?

ហានៈ ស្នាក់អត់ទេ ធ្វើតូបខ្លួនឯង ក្រាលកន្ទេលសំពានលើរនាបឬស្សីយើងវែងខ្លួនយើងនិងធ្វើសំពានទៅ

សាវីណាៈ អញ្ចឹងអ្នកផ្សេងគេខ្វះអញ្ចឹងដែរហេះអ៊ុំ?

ហានៈ អ្នកផ្សេងបើគេប្ដីប្រពន្ធដំណាក់កងអី គេអត់អីទេ គេអ្នកមូលដ្ឋានគេមិនសូវទេអូយ៉ាប់តែយើងអ្នកថ្មីទេ

សាវីណាៈ ចុះអ្នកថ្មីដូចគ្នានិងអ៊ុំមានឃើញខ្វះទេ?

ហានៈ ខុះដៃរដូចតែគ្នាអញ្ចឹង ធ្វើគួបនៅអូនតាមកង ហើយម្តងនោះទៅស្ទួងក្រាលក្រណាត់ កៅស៊ូលើក្រណាត់សើមនិងណាំ ភ្លៀងទទឹកមាំពេក ភ្លៀងផងអីផង ក្រាលលើនិងដេក ទៅ អើយយ៉ាប់ណាស់អូនអើយ

សាវីណាៈ ចុះមានធ្លាប់លឺថា នៅកន្លែងផ្សេងក៏មានគេខុះកន្លែងស្នាក់ដែរទេ?

ហានៈ កន្លែងគេផ្សេងដូចគ្នាអូន តែចេញកងដូចគ្នាទាំងអស់ នរណាក៏ដូចនរណាដែរ

សាវីណាៈ ចុះអ៊ុំធ្លាប់ជាប់ឃុំឃាំងទេ?

ហានៈ អត់ដែរទេ

សាវីណាៈ ចុះដែលឃើញនរណាមួយជាប់គុកទេ?

ហានៈ ជាប់គុកមានតែពួយុគនិង គាត់ជាប់ណា ជាប់ហើយគេលេងមកវិញណាអូន

សាវីណាៈ អូ! តែអ៊ុំអត់ដែលឃើញនៅក្នុងគុកទេហេះ?

ហានៈ អត់ដែលឃើញទេ

សាវីណាៈ តែធ្លាប់លឺណាំ?

ហានៈ ចាំ គេមិនដែលឲ្យទៅឃើញទេណាអូន គេមិនដែលឲ្យយើងដើរទៅណាទេ យើងមាន ដែលហ៊ានដើរណាំ

សាវីណាៈ ជិនាន់និងអ៊ុំមានដែលត្រូវរបួសអីធ្ងន់ទេអ៊ុំ?

ហានៈ អ៊ុំដែលត្រង់ថ្ងាះចង្កេះនិងទេ ដល់របួសអីខ្ញុំមិនដែលទេ

សាវីណាៈ ចុះដែលឃើញអ្នកណាត្រូវរបួស ត្រូវកាំបិតអី កាប់ចបអីត្រូវទេ មានទេអ៊ុំ?

ហានៈ ដូចជាភ្លេចអស់ហើយអូន យូរពេក

សាវីណាៈ ចុះមានដែលលឺទេអ៊ុំថានៅកន្លែងណាមួយផ្សេងទៀតគេត្រូវរបួសអីដែរណា?

ហានៈ ដូចជាមិនដែលលឺផង ខ្ញុំអត់ដែលដឹងផងអូន មានតែគេយកទៅវ៉ៃចោល ដូចថាអូន ឯងខុសសីលធម៌អីអញ្ចឹងទៅគេយកទៅធ្វើបាប គេឲ្យរែកដីអីអញ្ចឹងទៅណាអូន និង ហើយ ហើយនិងគេយកទៅវ៉ៃចោលអីអញ្ចឹងទៅ ហើយយប់ឡើងទៅយាមអីអញ្ចឹង ទៅ អ្នកដែលការហើយអត់ដេកជាមួយគ្នាអីអញ្ចឹងទៅណា អានិងដែលដឹង ដែលលឺ

សាវីណាៈ អូ! មានអញ្ចឹងទៀតណាំ?

ហានៈ និងហើយ ដូចថាអូនឯងប្តេជ្ញាឲ្យអូនឯងអញ្ចឹងទៅ យប់ឡើងគេតាមដានអូនឯងទៅ នរណាដេកលើគ្រែ នរណាដេកក្រោមគ្រែអីអញ្ចឹងទៅ អានិងគេតាមដានទៅមើល រាល់យប់ណាអូន គេឲ្យដេកជាមួយគ្នាអញ្ចឹងទៅណាអូន អានិងខ្ញុំដែលលឺ តែរឿង ជាប់គុកអីអត់អត់ដែលឃើញទេអូន

សាវីណា: ចុះអ៊ុំជំនាន់និងអ៊ុំរត់ពីកន្លែងមួយទៅកន្លែងមួយអញ្ចឹងណា អ៊ុំមានដែលជួបគេប្រយុទ្ធគ្នាទល់គ្នាទេអ៊ុំ? គេបាញ់គ្នាអីណា?

ហាន: បាញ់គ្នាកាលពីអាពតអត់ទេ តែកាលពីគេបាញ់វៀតណាមចូលអានិងដែល

សាវីណា: អ៊ុំនៅកន្លែងគេបាញ់គ្នានិងដែលហេះ?

ហាន: ចា៎ នៅនេះ នៅភូមិជិតនេះ និងខ្ញុំនៅមុខទព្វគេហើយ ខ្ញុំរត់ កាលនិងអត់ដឹងថាគេមកដាក់ទព្វនៅនិងណាអូន ដល់ហើយរត់

សាវីណា: ចុះអ៊ុំមានឃើញគេបាញ់ប្រយុទ្ធគ្នាទេ?

ហាន: ខ្ញុំដែលតែកាលអាពតអូន ចុះមកម្តងហើយគេបាញ់និងគេបាញ់គ្រួសារខ្ញុំមកធ្វើស្រែនិងណា៎ គេបាញ់ត្រូវជើងគោនិងណា គេបន្តក់ត្រូវជើងគោ

សាវីណា: ចុះធ្លាប់លឺថានៅកន្លែងណាផ្សេងទៀតគេបាញ់គ្នាអញ្ចឹងដែរអត់អ៊ុំជំនាន់និង?

ហាន: ដែលលឺដែរនិង ពួកនេះនិងគេចុះបាញ់គ្នា អាពតទាហាននិងណា បាញ់មានអីត្រូវរបួសតែញ៉ឹកនិង ខ្ញុំនៅក្នុងគេបាញ់គ្នាញ៉ឹកសឹងអីនិងអូន

សាវីណា: ចុះជំនាន់និងអ៊ុំមានដែលគេណែនាំឲ្យផ្លាស់ប្តូរគំនិតអ៊ុំអីទេ? គេហៅទៅអប់រំណែនាំអីណា?

ហាន: អីក៏មិនដែល គេប្រជុំហុះ

សាវីណា: គេប្រជុំទាំងអស់គ្នាហេះអ៊ុំ?

ហាន: គេប្រជុំទាំងអស់គ្នា

សាវីណា: ចុះនៅកន្លែងផ្សេងគេប្រជុំអញ្ចឹងដែរអត់អ៊ុំ?

ហាន: នៅកន្លែងផ្សេងគេប្រជុំដែរ ប្រជុំរាល់អាទិត្យនិងអូន ដូចថាថ្ងៃ១០ ថ្ងៃ២០អញ្ចឹងគេប្រជុំម្តងអូនណា៎

សាវីណា: ចុះអ៊ុំមានដែលលឺគេរំលោភនារីភេទពីជំនាន់និងទេអ៊ុំ?

ហាន: ជំនាន់និងមានអូន ដូចថាគ្រួសារយើងនៅនេះអញ្ចឹង ដូចថាមេម៉ាយអញ្ចឹងមុននិងវាឲ្យយើងមានគ្រួសារ ប្តេជ្ញាជាមួយនរណា គំណាងកងនិងគេសុទ្ធស្រលាញ់ណាអូនហើយវាប្តេជ្ញាឲ្យ រំលោភហើយអញ្ចឹង វាប្តេជ្ញា និងមាន ខ្ញុំលឺ

សាវីណា: តែអ៊ុំអត់ដែលឃើញទេហេះ?

ហាន: អត់ដែលឃើញទេ ខ្ញុំដែលលឺ

សាវីណា: ចុះជំនាន់និងអ៊ុំមានដែលត្រូវគេបង្ខំឲ្យនៅដាច់ដោយឡែកទេ?

ហាន: ខ្ញុំដែលគេយកចេញពីកូននិង ខ្ញុំទៅតែតាមកងនិង

សាវីណា៖ ប៉ុន្តែអត់ដែលនៅតែឯងទេហេះ?

ហាន៖ អត់ដែលនៅតែឯងទេ

សាវីណា៖ ចុះដែលឃើញនរណាគេនៅតែឯង អត់មាននៅជាមួយអ្នកភូមិទេ?

ហាន៖ អត់ដែលឃើញផង

សាវីណា៖ លឺក៏មិនដែលដែរ?

ហាន៖ ចា៎ អត់ដែលឃើញផង

សាវីណា៖ ចុះអ៊ុំមានដែលជួបហេតុការណ៍ណាមួយប៉ិះនិងស្លាប់ខ្លួនទេអ៊ុំ?

ហាន៖ មានរឿង មានតែរឿងរត់និងអូន

សាវីណា៖ រឿងគេប្រយុទ្ធគ្នានិងហេះ?

ហាន៖ ចា៎ គេបាញ់គ្នាអីនិង

សាវីណា៖ តែអ៊ុំមានដែលជួបរឿងប៉ិះនិងស្លាប់ តែអត់ស្លាប់វិញណា?

ហាន៖ អត់ដែលផង

សាវីណា៖ តែដែលឃើញនរណាជួបរឿងដូចខ្ញុំនិយាយមិញទេ ជួបរឿងប៉ិះស្លាប់តែអត់ស្លាប់វិញណា?

ហាន៖ ដែលឃើញពួយុគនិង គេយកទៅជាប់គុកនិងនិងហើយ តែគាត់អត់ស្លាប់វិញនិងណា

សាវីណា៖ ចុះធ្លាប់លឺទេអ៊ុំ?

ហាន៖ អូ! ខ្ញុំដែលម្តងអូន ដែលកាលនិងគេគាស់ដំឡូងខ្ញុំដាំណា៎ ខ្ញុំមកពីកង ខ្ញុំដាំយប់ៗ ដល់ហើយខ្ញុំមកដល់ឃើញប្រធានអាពួកសេដ្ឋកិច្ចគេគាស់ណា៎ គេគាស់អស់ហើយ ហើយខ្ញុំមកដល់ចង់កាយស្ងោស៊ីនោះ ដល់ស្ងោដំណាងកងស្រីនិងមក គាត់មកខ្ញុំហៅគាត់ហូបបងខ្ញុំនិងគាត់ថា ហែ្វងឆាប់ហើយល្ងាចនិងហេះ គាត់ថាអញ្ចឹងណា តែមានភ្លើងដុះ ណាឆាប់ហើយ ខ្ញុំថា ខ្ញុំឆាប់ក៏ឆាប់ទៅ លែងគិតហើយ ថាអញ្ចឹងណា ខ្ញុំហៅតំណាងកងនិងហូប ហូបហើយគាត់ទៅបើកអង្គប្រជុំណាអូន ខ្ញុំភ័យណាស់ ភ័យមែននិងណាថាស្លាប់ហើយមួយពេលនិង ដល់ហើយដល់តែពេលប្រជុំគេថា ក្រោយខ្ញុំឲ្យសួរគាត់អ្នកដាំសិន តំណាងកងខ្ញុំគាត់ថាអញ្ចឹងណា គាត់ខំមកពីនោះមកដាំទាំងយប់ទាំងអា គ្រាតដាំជាមួយកូន ប្រឹងចំរើនសហករណ៍យើងប៉ុណ្ណឹងហើយមិចទៀត ហើយឲ្យសួរ គាត់សិនដល់ហើយដំឡូងនិងគាត់ទុកឲ្យខ្ញុំគាស់ស្ងោស៊ីអស់ទៅព្រោះខ្ញុំអ្នកធ្វើណា

សាវីណា៖ ពេលនិងគេរៀបនិងយកអ៊ុំទៅហើយហេះ?

ហានៈ ចាំ ខ្ញុំភ័យណា ខ្ញុំថាអន្តប្រជុំនិងគេរៀបនិងយកខ្ញុំទៅហើយ ដល់ហើយអត់អីវិញទៅ តំណាងកងខ្ញុំគាត់អ្នកតស៊ូណា គាត់អ្នកប្រាប់វិញណា

សាវីណាៈ ចុះអ៊ុំដែលលឺនៅកន្លែងផ្សេងមានគេអញ្ចឹងដែរទេអ៊ុំ? ដូបរឿងបិះតែនិងស្លាប់ខ្លួនអញ្ចឹងដែរទេ?

ហានៈ កន្លែងផ្សេងមានតែពួយុគនិងកូន និងបិះតែនិងស្លាប់ដែរនិងណា គេយកទៅហើយ

សាវីណាៈ ចុះពេលទៅគ្មារអីនិង អ៊ុំបែកពីកូនអស់ហើយ?

ហានៈ ចាំ បែកអស់ហើយ

សាវីណាៈ គេមានបន្ទុំអ៊ុំដែរទេ?

ហានៈ គេហៅទៅម៉ងអូន ទិសដៅគេ បើយើងមិនទៅមិនបានអូន មិនបន្ទុំក៏ដូចបន្ទុំដែរណានិងវាដាក់វិន័យអញ្ចឹងម៉ង

សាវីណាៈ អ្នកផ្សេងអញ្ចឹងដែរអ៊ុំ?

ហានៈ អ្នកផ្សេងក៏អញ្ចឹងដែរ ដូចតែគ្នា គេឲ្យទៅ តែកន្លែងគេឲ្យទៅ ត្រូវតែទៅអញ្ចឹងម៉ង អូន

សាវីណាៈ ចុះអ៊ុំធ្លាប់លឺ ធ្លាប់ឃើញគេសម្លាប់បងប្អូនឯងពីសម័យនិងទេអ៊ុំ ដូចថា បងចង់សម្លាប់ប្អូន កូនចង់សម្លាប់ឪពុកអីកាលពីសម័យនិងណា?

ហានៈ អត់ដែលលឺទេអូន

សាវីណាៈ ចុះអ៊ុំមានដែលលឺបងប្អូន ញាត្តិមិត្តអីស្លាប់ ដែលអ៊ុំយល់ថាខុសពីធម្មតាទេអ៊ុំ?

ហានៈ ស្លាប់ប្លែកពីធម្មតាមានតែវ៉ៃនិងណាអូន

សាវីណាៈ អ៊ុំយល់ថាវាប្លែកណា វាខុសពីធម្មតាណា វាមិនមែនដូចធម្មតាណា?

ហានៈ អានិងប្លែកហើយគេយកទៅវ៉ៃនិងណាអូន

សាវីណាៈ អ៊ុំធ្លាប់ឃើញទេ?

ហានៈ នៅនេះឃើញតែគេ អត់ឃើញបងប្អូនឯង បងប្អូនឯងនៅឆ្ងាយណាស់ ឃើញតែគេយកទៅ ដឹកនៅណាអូន គានោះអីគេចងទៅដូចជ្រូកអញ្ចឹង គេចងទៅតែម្តង

សាវីណាៈ ធ្លាប់តែឃើញគ្រួសារគេទេហេះ?

ហានៈ ចាំ ឃើញគ្រួសារគេ គ្រួសារខ្ញុំអត់ដែលឃើញដងនិងព្រោះបងប្អូននៅឆ្ងាយណោះណាអូន

សាវីណាៈ ចុះអ៊ុំមានដែលឃើញគេសម្លាប់មនុស្សទេអ៊ុំ?

ហានៈ គេសម្លាប់មនុស្សខ្ញុំអត់ដែលឃើញទេ

សាវីណាៈ ធ្លាប់លឺថាគេសម្លាប់មនុស្សទេអ៊ុំ?

ហានៈ លីគ្រាន់តែលឺអ៊ុំ គ្រាន់តែអត់ដែលឃើញផង

សាវីណាៈ អ៊ុំមានដែលវង្វែងឬគេចាប់ដាក់កន្លែងណាមួយដែលអ៊ុំអត់ស្គាល់ទេ?

ហានៈ អត់ទេ

សាវីណាៈ ចុះមានដែលឃើញនរណាគេដែលគេចាប់ដាក់កន្លែងណាមួយដែលគេអត់ស្គាល់ហើយ ឬមួយក៏គេវង្វែងអីណា អ៊ុំមានដែលធ្លាប់ឃើញទេ?

ហានៈ គេវង្វែងអត់ទេអូន មានតែដែលឃើញអ្នកអត់ឃ្លាន មករកស៊ីហើយគេចាប់ណា កាលនឹងនៅភូមិនោះ គេចាប់ដាប់ណាអូន អានិងដូចថាយើងមកដូរអីអញ្ចឹង ចាប់ អត់មានច្បាប់ទំលាប់គេអាពតអញ្ចឹងណា៎ គេចាប់យើងហើយ

សាវីណាៈ ចុះដែលធ្លាប់លឺនៅកន្លែងផ្សេងទៀតទេអ៊ុំរឿងគេចាប់អីនិង?

ហានៈ អត់ដែលលឺទេ

សាវីណាៈ អ៊ុំដែលគេវាយ គេធ្វើបាបអីដែរអ៊ុំ?

ហានៈ ដែលតែធ្វើការធ្ងន់អូន បើវាយគេអត់ដែលវាយទេ តែគ្រាន់តែដែលធ្វើការធ្ងន់ ធ្វើ ហួសកម្លាំងដែរនិងណាអូន រែកដី ហើយខ្ញុំនៅតែកងមុខទេអូន ហើយស្ទូង៩នាក់មួយ ហិចតាក៏ដែលស្ទូងដែរអូន

សាវីណាៈ ធ្វើការធ្ងន់រហូតដល់ថ្ងោះចង្កេះអីនិងហេះ?

ហានៈ ចា៎ ធ្វើការធ្ងន់រហូតដល់ថ្ងោះចង្កេះនិង

សាវីណាៈ ចុះដែលឃើញអ្នកផ្សេងត្រូវគេវាយធ្វើបាប ឬគេដាក់ទណ្ឌកម្មដែរអត់អ៊ុំ?

ហានៈ ដែលឃើញតែអ្នកមានខូចគ្នាអូនណា មានគ្រួសារ កាលនិងពីមុនមេម៉ាយ មេម៉ាយ ហើយមានគ្រួសារដូចស្រលាញ់គ្នាអញ្ចឹងទៅណាអូន គេយកទៅធ្វើទោសគេឲ្យទៅរែក ដីអីអញ្ចឹងទៅ

សាវីណាៈ ចុះធ្លាប់លឺគេធ្វើបាប ធ្វើទារុណកម្មអីទេ ក្រៅពីអ៊ុំធ្លាប់ឃើញ?

ហានៈ វាលឺដែរអូន តែយើងមិនដែលបានឃើញនិងភ្នែក ឃើញនិងភ្នែកឃើញតែគេធ្វើបាប ខុសសីលធម៌អីនិងណា៎ ហើយដូចតំណាងកងយុវជនអីនិង មីនិងគេធ្វើបាបអីនិងណា អូន គេធ្វើទារុណកម្មយើង

សាវីណាៈ ចុះក្រៅពីអ៊ុំរៀបរាប់ប្រាប់ខ្ញុំនិងណា អ៊ុំមានដែលជួបហេតុការណ៍ណាផ្សេងដែលគួរឲ្យ រន្ធត់ទេ ដែលធ្វើឲ្យជីវិតអ៊ុំប៉ិះតែនិងរងគ្រោះទេអ៊ុំ?

ហានៈ ប៉ិះនិងស្លាប់មានតែរត់តាមយួននិងណាអូន និងប៉ិះតែស្លាប់ដែរនិងណា រត់ដល់នេះ ហើយអាពតដេញបាញ់និង រៀបស្លាប់ដែរនិង កាលនិងភ័យមែនទែនដែលលើក

យាយមួយរត់លើកកាត់ភក់ ដល់ពេលបាត់ហត់ បាត់ភ័យលើកអត់រួចផង លើកមិន រួច យាយនិង ពរគាត់មិនរួចទេ ហើយដល់ពេលភ័យពរគាត់រត់កាត់ភក់តាមប្រឡាយ រត់រួចណាអូន ដល់ពេលហួសបាត់ភ័យអញ្ចឹងទៅ លើកគាត់ លើកមិនរួចផង ចុះធ្ងន់ មនុស្ស ចាស់ហើយលើកមិនរួចផង

សាវីណា: ចុះអ៊ុំមានជួបនរណាផ្សេងទៀតជួបដូចអ៊ុំអញ្ចឹងទៅ ជួបអ្នកផ្សេងរត់អញ្ចឹងដែរហេះ អ៊ុំ?

ហានៈ រត់មានតែបងប្អូនកូនចៅខ្ញុំនិង រត់មានគ្នាដែរនិងណា ម៉ានេះនិង តាំងពីដន្ទងខ្ញុំអីនិង ហើយរត់បែកគ្នានិង

សាវីណា: ចុះធ្លាប់លឺទេអ៊ុំ ថាគេរត់គេអី ហើយប៊ិះនិងគេបាញ់អីអញ្ចឹងណា?

ហានៈ ហីមិនលឺ អានិងចេះតែលឺហើយ រត់ទៅគេបាញ់ ហើយកាលពីនៅកងជាមួយគ្នា ពូ មួយនោះរត់ៗទៅគេតាមរកអត់ឃើញគេ គេថាយើងនិងចូលដៃជាមួយយួនណា ហើយគាត់រត់ចេញបាត់ទៅ ពូនិងមិនដឹងទៅណា ចេញបាត់ទៅ

សាវីណា: ចុះអ៊ុំក្នុងចំណោះហេតុការណ៍ដែលអ៊ុំជួបជំនាន់អាពតនិងណា ហេតុការណ៍ណាដែលឈឺ ចាប់ជាងគេណាអ៊ុំ?

ហានៈ វាឈឺចាប់ជាងគេ ឈឺចាប់អាបន្ទត់ចំណីនិងហើយអូន ហើយធ្វើបាបយើងនិង ធ្វើ បាបពលកម្មនិងណ៎ា ហើយនិងយកគ្រួសារយើងយកទៅសម្លាប់ចោលនិង អានិងឈឺ ខ្លាំងណាស់

សាវីណា: ក្នុងចំណោម២-៣រឿងនិង អាណាមួយដែលអ៊ុំឈឺចាប់ជាងគេបំផុតណា?

ហានៈ ឈឺចាប់ជាងគេបំផុត ឈឺចាប់សម្លាប់មនុស្សអូន យកប្ដីខ្ញុំ ឪពុកខ្ញុំ ប្អូន បង ប្អូនទាំង អស់អូនឯងមើល

សាវីណា: ចុះអ៊ុំមានដែលធ្លាប់គេវាយក្បាលអត់អ៊ុំ តាំងពីតូចមក?

ហានៈ តាំងពីតូចមកមិនដែលទេប្អូន ឪពុកម្ដាយខ្ញុំអត់ដែលវៃផង

សាវីណា: ចុះអ៊ុំដែលលង់ទឹកទេ

ហានៈ ដែល លង់ទឹកម្ដង

សាវីណា: លង់ពីអង្កាលអ៊ុំ

ហានៈ លង់និងជិតក្រមុំហើយអូន

សាវីណា: អាយុប៉ុន្មាន?

ហានៈ អាយុ ១៥ ឆ្នាំ

សាវីណា: ចុះអ៊ុំដែលចេះតែថប់ៗដង្ហើមទេ?

ហានៈ បេះតែរមូលៗឡើងលើ ចង់ក្អួតណា រាល់ថ្ងៃនិងវាបេះរៀងរៀងខ្លៀកៗអញ្ចឹងទៅ ចង់ស្ទុះ ចង់ក្អួតទៅណា ចង់ក្អួត ចង្អោរ

សាវីណាៈ តាំងពីពេលណាមកអ៊ុំ,

ហានៈ តាំងពីខ្ញុំចាប់ឈឺមក ៣ឆ្នាំហើយអូន

សាវីណាៈ ចុះអ៊ុំមានដែលសន្លប់ទេអ៊ុំ?

ហានៈ សន្លប់ដែលម្ដងដែរអូន

សាវីណាៈ ពីអន្កាល់

ហានៈ កាលពីការកូននិង ដល់ហើយវាតាំងម្ដងដែរអូន វាដូចជាបាត់ឈឹង

សាវីណាៈ ប៉ុន្មានម៉ោងទៅ?

ហានៈ មួយសន្ទុះដែរ កូនវាប្រចាប់ទៅអន់ដែរទៅ

សាវីណាៈ អ៊ុំខ្វល់ហេះ?

ហានៈ អានិងដូចជាខ្យល់ហើយអូន មិនអីទេមើលទៅ

សាវីណាៈ តែម្ដងនិងតើអី?

ហានៈ ចាំ៎ តែអារមូលនិងវាបេះតែរាងថប់ៗណា

សាវីណាៈ មកដល់ឥឡូវនិងនៅតែអញ្ចឹង?

ហានៈ ចាំ៎ កាលណាខ្ញុំដូចជា........................

Casseete 2
Side B

សាវីណាៈ អ៊ុំម៉ិញខ្ញុំបានសួរអ៊ុំពីហេតុការណ៍សម័យប៉ុលពតណា ហើយឥឡូវខ្ញុំចង់សួរអ៊ុំបន្តរទៀត ទាក់ទងនិងអារម្មណ៍អ៊ុំដែលអ៊ុំបានជួបឥឡូវនិងហេះ? អ៊ុំមានអារម្មណ៍ម៉ិចខ្លះដែលវាប៉ះពាលពីសម័យនិងមកណា ខ្ញុំចង់សួរអ៊ុំ អ៊ុំបេះតែគិតឬនឹកឃើញដល់សម័យប៉ុលពតនិង?

ហានៈ ដល់ឥឡូវវាសុកស្រួលទៅអូនអត់សូវនឹកដែរនិងណា បើដូចថាយើងចាប់មើលអីអញ្ចឹងវានឹកឃើញដែរនិងណា៎ ដូចថានឹកឃើញដែរនិងណា៎ពីរឿងវេទនាអីនិង

សាវីណាៈ ចុះពេលអ៊ុំនឹកទៅដូចជានៅថ្មីៗទេអ៊ុំ?

ហានៈ ចាំ៎ តែនឹកឃើញដូចជានៅទើមៗសោះ ដែលពេលយើងនេះអញ្ចឹងទៅវាឆ្ងាយដែរ ហើយតែនឹកឃើញដូចជានៅឆាប់សោះ

សាវីណា៖ អ៊ុំនឹកឃើញថ្មីៗ អញ្ចឹងញឹកញាប់ប៉ុណ្ណាដែរអ៊ុំ?

ហាន៖ វាថ្មីៗ ញឹកញាប់និងវាល្មមដែរអូន វាមិនខ្លាំងណាស់ណាទេ ដូចថាវារសាយចិត្តតិច ហើយឥឡូវទៅ ដូចថាយើងរកស៊ីទៅ វាភ្លេច ដូចថាវាស្ងាប់យូរហើយវារំសាយចិត្តតិចទៅអូនណាំ

សាវីណា៖ ចុះអ៊ុំដែលយល់សប្តិអាក្រក់ទេយប់ៗ ឡើង?

ហាន៖ យប់ឡើងដែលដែរនិងណាអូន យល់សប្តិឃើញវ៉ៃចោលអីក៏មានដែរ

សាវីណា៖ ឥឡូវនៅទេអ៊ុំ?

ហាន៖ ឥឡូវក៏នៅដែរ តិចៗ យល់សប្តិឃើញដែរនិង

សាវីណា៖ ញឹកញាប់ទេ?

ហាន៖ ញឹកញាប់ដែរនិង យល់សប្តិឃើញអាពតញឹកណាស់អូន យល់សប្តិឃើញគេឲ្យទៅនៅនោះអី គេដេញវ៉ៃអីក៏ដែលដែរនិងណាំ ក្នុងខែនិងយល់សប្តិឃើញ២-៣ដងហើយ ណេះខ្ញុំចេះតែនឹកឃើញស្រម័យ ចេះតែយល់សប្តិឃើញ

សាវីណា៖ ចុះអ៊ុំមានដែល ដូចរាល់ថ្ងៃអញ្ចឹងមានដែលគិតថាមិនចង់ជួបជាមួយអ្នកផ្សេង មិនចង់រវីរវល់ ចង់នៅតែឯងអី មានដែលគិតអញ្ចឹងទេអូន?

ហាន៖ អត់ទេ

សាវីណា៖ ចុះពេលដែលអ៊ុំជួបរឿងសប្បាយ អ៊ុំជួបរឿងសប្បាយជាមួយគេដែរអត់ទេ ពេលមានរឿងសប្បាយដូចជាចិត្តអ៊ុំអត់សប្បាយណាំ?

ហាន៖ ទៅជាមួយគេអញ្ចឹងសប្បាយដែរអូន អត់អីទេ ទៅបុណ្យទៅទានអីអញ្ចឹងសប្បាយដែរនឹកឃើញ

សាវីណា៖ ចុះអ៊ុំឆាប់ភ្ញាក់ផ្អើល ឆាប់ភ័យទេពេលមានរឿងអីមួយអញ្ចឹងណា?

ហាន៖ ភ័យអូន ឆាប់ភ័យណាស់ តែភ័យបែកញើសស្ងួតទឹកមាត់បណ្តោយ

សាវីណា៖ ពេលអ៊ុំជួបរឿងអីមួយ ហើយអ៊ុំភ័យណា អ៊ុំភ័យខ្លាំងទេ?

ហាន៖ ភ័យខ្លាំងដែរនិងណាំ ភ័យរកកន្លែងមិនឃើញ ភ័យខ្លាំងដែរនិងណាអូន

សាវីណា៖ ចុះអ៊ុំគិតទៅលើរឿងអីមួយអញ្ចឹង អ៊ុំប្រមូលអារម្មណ៍គិតលើរឿងនិងបានទេអ៊ុំ?

ហាន៖ ហឺមិនបានអូន

សាវីណា៖ អត់អីទេហេះ?

ហាន៖ ចាំ

សាវីណា៖ ចុះរាល់ថ្ងៃនិង អ៊ុំពិបាកសំរានទេអ៊ុំ?

ហានៈ ពិបាកសំរានដែរនិង តាំងពីមានចោនិងមកសំរានអត់លក់ទេអូន ម៉ោង ១២ ល្ងាច មិញម៉ោង ១គត់ ភ្លែព្រះពេក ចេះតែខ្លាចណាអូន

សាវីណាៈ ពិបាកសំរានអញ្ចឹងញឹកញាប់ទេអ៊ុំ?

ហានៈ ញឹកញាប់ដែរនិងណា

សាវីណាៈ មួយខែអញ្ចឹងប៉ុន្មានដង?

ហានៈ មួយខែអញ្ចឹង ច្រើនដងដែរនិងណា ញឹកដែរនិងយប់សំរានអត់សូវលក់ទេ

សាវីណាៈ ចុះរាល់ថ្ងៃអ៊ុំចេះតែមានអារម្មណ៍ប្រុងប្រយ័ត្នខ្លួនជាប់ទេអ៊ុំ ខ្លាចគេមកបៀតបៀន ខ្លាចគេមកធ្វើបាបអីណ៎?

ហានៈ ខ្លាចដែរ ភ័យប្រយ័ត្នដែរនិង

សាវីណាៈ ហេតុអី?

ហានៈ នឹកឃើញដែរ យប់ៗខ្ញុំមិនដែលហ៊ានដេកទេឥឡូវ ខ្លាច

សាវីណាៈ អ៊ុំនឹកឃើញចេះតែខ្លាចគេមកអញ្ចឹង អ៊ុំនឹកឃើញខ្លាំង តិចតួច ឬល្មមអូន?

ហានៈ ខ្លាចខ្លាំងដែរនិងណាអូន គេខ្លះគេគិតថាមិនខ្លាច តែខ្ញុំខ្លាច

សាវីណាៈ ចុះពេលមានរឿងអីអញ្ចឹង រឿងនិងល្មមៗទេ អ៊ុំគិតថា អ៊ុំឆាប់ខឹងអីអត់អ៊ុំ?

ហានៈ ពេលមានរឿងអីនិងឆាប់ខឹងដែរនិងអូន តែខឹងហើយរួចហើយ មិនសូវចេគុំទេ ចេះ ខឹងតែមិនសូវចេះគុំទុកទេណ៎ ខឹងហើយថាម៉ង

សាវីណាៈ តែឆាប់ខឹងអញ្ចឹង ឆាប់ខ្លាំង តិចឬល្មម?

ហានៈ ឆាប់ខឹងខ្លាំងដែរនិងណ៎ តាំងពីនេះនិងមកដូចជាឈឺពេកនៅក្នុងក្បាល តែឈឺក្បាល ដេកមិនលក់ទេអូន

សាវីណាៈ ចុះពេលណាដែលអ៊ុំចាប់ផ្តើមគេងអត់លក់អញ្ចឹង?

ហានៈ គេងអត់លក់ពេលយប់អូន

សាវីណាៈ អត់ទេប៉ុន្មានឆ្នាំហើយ?

ហានៈ គេងមិនលក់និង ១ឆ្នាំនិងមកអូន បើកាលណាយប់អញ្ចឹង ល្ងាចមិញម៉ោង១គត់ ដល់ នឹកអញ្ចឹងទៅ គិតតិចទៅ គេងមិនលក់ម៉ង ហើយស្វាបៗ ប៉ុន្តែគេងមិនលក់ មិនដឹង យ៉ាងម៉ិច

សាវីណាៈ ចុះរាល់ថ្ងៃពេលអ៊ុំធ្វើកិច្ចការអីអញ្ចឹង អ៊ុំចាប់អារម្មណ៍និងការងារប្រចាំថ្ងៃរបស់អ៊ុំទេ អ៊ុំ?

ហានៈ ការងាររាល់ថ្ងៃនិងធ្វើដែរ កាលពីមុនគេឲ្យទៅបង្រៀន តែគ្រាន់តែថាមកវិញឆាប់ ភ្លេច ឥឡូវឆាប់ភ្លេចណាស់ វាមិនសូវចាំដូចមុន

សាវីណាៈ អ៊ុំការងាររាល់ថ្ងៃចាប់អារម្មណ៍ចង់ធ្វើវាដែរហេះ?

ហានៈ ចាំ

សាវីណាៈ ចុះអ៊ុំមានដែលគិតថា ទៅមុខរកអនាគតអត់ឃើញ គ្មានក្ដីរំពឹង គ្មានក្ដីរំពឹងអីអត់?

ហានៈ អត់មានសង្ឃឹមអីទេ មានសង្ឃឹមអីបើយើងចាស់ហើយ បានអីសង្ឃឹម

សាវីណាៈ ចុះអ៊ុំមានដែលទៅមុខទៅអត់មានកូនរំពឹងអីទេ,

ហានៈ អត់អីទេ កូនចៅខ្ញុំអត់អីទេ កូន៤និង

សាវីណាៈ ចុះអ៊ុំចង់លែងគិតពីសម័យអាពតនិងដែរអត់អ៊ុំ?

ហានៈ សម័យអាពតនិងហេះ?

សាវីណាៈ ចាំ

ហានៈ ឥឡូវនិងវាមិនចង់ឲ្យឃើញ មិនចង់ឲ្យលឺ តែអាចចិត្តវានៅតែនឹកឃើញអញ្ចឹងអូន វាមិនភ្លេច វាមិនភ្លេច

សាវីណាៈ ពេលដែលអ៊ុំនឹកឃើញទៅដល់សម័យនោះអញ្ចឹងណា នៅក្នុងខ្លួនអ៊ុំមានធ្វើទុកអីទេ?

ហានៈ អត់អីទេអូន ធម្មតា

សាវីណាៈ ចុះមកដល់ឥឡូវអ៊ុំដែលគិតថា អ្នកផ្សេងដូចជាមិនយល់ពីការលំបាករបស់អ៊ុំ អ៊ុំធ្លាប់លំបាកគេយកបងប្អូនទៅសម្លាប់អីអញ្ចឹងណា? ឥឡូវនិងអ្នកផ្សេងគេអត់យល់ណា?

ហានៈ គេអត់យល់ផង

សាវីណាៈ អ៊ុំមានដែលគិតថាគេអត់យល់ពីរឿងរ៉ាវរបស់អ៊ុំទេ?

ហានៈ គិតដែរនិង នឹកឃើញដែរ តែច្រើនគ្នាគេមិុចនិងគិតឃើញដល់យើង នឹកឃើញអញ្ចឹងដែរនិងណា

សាវីណាៈ អ៊ុំធ្វើការងាររាល់ថ្ងៃពិបាកអត់អ៊ុំ?

ហានៈ រាល់ថ្ងៃនិងមិនពិបាកអីប៉ុន្មានទេ ល្មមដែរ មានកម្លាំង តែមានធ្វើអី មានតែធ្វើស្រែអីបន្តិចបន្តួចជួយកូននិង

សាវីណាៈ អ៊ុំដែលបន្ទោសខ្លួនដែលមានរឿងជួបកាលពីសម័យអាពតនិងទេ?

ហានៈ អត់គិតអីទេអូន ត្រូវកើតមកអញ្ចឹង

សាវីណាៈ ចុះមានដែលបន្ទោសខ្លួនឯងដែលមានជីវិតរស់មកដល់សព្វថ្ងៃនិងទេអ៊ុំ?

ហានៈ នឹកឃើញដែរអូន កាលណាពិបាកមិុចក៏មិនងាប់កាលនិងឲ្យហើយទៅ

សាវីណាៈ ចុះឥឡូវ?

ហានៈ ឥឡូវនឹកថាអាណិតកូន អាកូនចៅនិងនៅមើលវាទៅ ធ្វើមិុច ចង់ស្លាប់អី

សាវីណា: ចុះអ៊ុំមានដែលមានអារម្មណ៍ថាអស់សង្ឃឹមទេរាល់ថ្ងៃនិង?

ហាន: អស់សង្ឃឹមអីទៅ?

សាវីណា: ដូចថាគ្មានសង្ឃឹមអីនិងណា មានដែលគិតអញ្ជឹងអត់?

ហាន: អីក៏មិនគិតអូន នឹកឃើញថា អត់មានអីសង្ឃឹមទេរាល់ថ្ងៃ អត់មានប្រាក់កាសអីនិង គ្មានរកបានអីខ្លួនឯង

សាវីណា: អ៊ុំគិតអញ្ជឹងខ្លាំងប៉ុណ្ណាដែរអ៊ុំ?

ហាន: គិតកាលណាយប់ណានេះទៅគិតទៅ តែលុយចាយនិងវាគ្មានអូន ព្រោះខ្វះអាបញ្ហា លុយនិងម៉ង

សាវីណា: អ៊ុំគិតសឹងតែរាល់យប់ ឬយូរៗគិតម្ដងទេ?

ហាន: គិត អាណានេះគិតសឹងរាល់យប់ដែរនិង ដេកទៅ ថ្ងៃណាគិតទៅដេកអត់លក់ទេអូន គិតអញ្ជឹងទៅគេងមិនលក់ទេ

សាវីណា: ចុះអ៊ុំមានដែលគិតខ្មាស់គេថា អ៊ុំជួបរឿងជំនានអាពតអីអញ្ជឹងទេ?

ហាន: អត់ខ្មាស់ទេ

សាវីណា: អ៊ុំមានដែលគិតឆ្ងល់ថា រឿងរ៉ាវពីជំនាន់អាពតនិងកើតឡើងចំពោះអ៊ុំទេ? មានដែល ឆ្ងល់ខ្លួនឯងអញ្ជឹងទេ?

ហាន: ឆ្ងល់អាពតម៉ិចខ្លួនឯងទៅអញ្ជឹង ហើយខ្លួនឯងទៅអញ្ជឹងហេះ,

សាវីណា: ចា៎

ហាន: និងមិនអីទេអូន ព្រោះមានអ្នកចង់ព្យាបាទអញ្ជឹងហើយ តាំងពីមុនមក

សាវីណា: ចុះអ៊ុំមានដែលគិតថាខ្លួនឯងដូចជាចង់ឆ្កួតទេពេលដែលគិតយូរៗទៅ?

ហាន: អត់ទេ ខ្ញុំអត់គិតថាចង់ឆ្កួតចង់អីទេ

សាវីណា: ចុះមានដែលគិតថាមានតែខ្លួនអ៊ុំម្នាក់ទេដែលពិបាកកាលពីជំនាន់ប៉ុលពតណា៎ គេផ្សេង ដូចជាមិនពិបាកដល់អ៊ុំអីអញ្ជឹងណា??

ហាន: ចា៎ គិតដែរនិង កាលនិងគិតដែរព្រោះគេតាមដានខ្ញុំពេក

សាវីណា: អត់ទេរាល់ថ្ងៃណា៎

ហាន: អូ! រាល់ថ្ងៃហេះ?

សាវីណា: ចា៎

ហាន: រាល់ថ្ងៃអត់ទេ មានគេពិបាកជាងខ្ញុំខ្លាំងដែរនិងណា

សាវីណា: ចុះអ៊ុំដែលគិតថាអ្នកផ្សេងសុទ្ធតែជាសត្រូវនិងអ៊ុំទេអ៊ុំ?

ហានៈ អត់ទេ គេមិនមែនសត្រូវទាំងអស់ទេអូន

សាវីណាៈ ចុះមានដែលគិតថាអ្នកផ្សេងដូចជាពឹងពាក់អត់បានអីទេ អ្នកដែលនៅជុំវិញអ៊ុំនិង?

ហានៈ ជុំវិញខ្លួនមានអ្នកពឹងពាក់បានដែរតើអូន មានអី

សាវីណាៈ ចុះអ៊ុំបានធ្វើអីមួយអញ្ចឹងណា ហើយអ្នកផ្សេងមកប្រាប់អ៊ុំថា អ៊ុំបានធ្វើអញ្ចេះៗ តែអ៊ុំនឹកអត់ឃើញ មានដែលអញ្ចឹងទេអ៊ុំរាល់ថ្ងៃ?

ហានៈ អត់ដែលទេ ខ្ញុំមិនដែលធ្វើអី ហើយអត់នឹកឃើញទេ

សាវីណាៈ ចុះអ៊ុំមានដែលនៅក្នុងខ្លួនអ៊ុំតែមួយទេណា តែអ៊ុំបំបែកខ្លួនជាពីរ អារម្មណ៍មួយកំពុងធ្វើមួយកំពុងតែតាមដានអីណា មានអារម្មណ៍អញ្ចឹងទេ?

ហានៈ កំពុងធ្វើ កំពុងតាមដានអី បែកជាពីរទៅ? បែកផ្សេងទៅអី,

សាវីណាៈ ចា៎ អារម្មណ៍បែកជាពីរណា?

ហានៈ អត់ទេ

សាវីណាៈ ចុះអ៊ុំមានដែលមានអារម្មណ៍ថា នរណាដែលអ៊ុំទុកចិត្តហើយ បែរជាក្បត់អ៊ុំវិញមានដែលទេ?

ហានៈ មានដែរនិងណាអូន ធ្លាប់រាប់អានគ្នាអញ្ចឹងហើយបែកបាត់ណា៎

សាវីណាៈ និងហើយមានទេ?

ហានៈ ហ៊ីក៏មានអូន មានតើ

សាវីណាៈ តែក្នុងអារម្មណ៍អ៊ុំមិនអីសោះ តែអ៊ុំគិតថា គេក្បត់ចិត្ត គេចង់ធ្វើទុកមកលើយើងវិញក្នុងអារម្មណ៍អ៊ុំមានចេះតែគិតអញ្ចឹងទេ?

ហានៈ អឺមិនមាន ខ្លះខ្ញុំជួយគេទៅ ខ្លះគេឲ្យទោសខ្ញុំវិញណាអូន

សាវីណាៈ មានច្រើនទេអូន

ហានៈ មានម្នាក់ ២នាក់និងអូន និងជួយកាលពីបែកវៀតណាមនិង វៀតណាមមូលនិង

សាវីណាៈ សំនួរខ្ញុំចប់ហើយអ៊ុំ រំខានអ៊ុំមួយល្ងាចហើយ

ហានៈ រំខានចុះអត់អីទេ

សាវីណាៈ អរគុណអ៊ុំច្រើន

ហានៈ ចា៎

-ចប់-